ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងធនធានទឹក និងឧតុនិយម

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍

## លើ

## វិស័យធនធានទឹក និងឧតុនិយម ដើម្បីរួមចំណែកក្នុងការអនុវត្ត
## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (២០០៩-២០១៣)

# មាតិកា

ទំព័រ

**ក-សេចក្តីផ្តើម** ........ ១

**ខ-សមិទ្ធផលក្នុងការអនុវត្តវិស័យធនធានទឹក និងឧតុនិយម រយៈពេល ៥ឆ្នាំ (២០០៤-២០០៨)** ........ ២

**១** ការរៀបចំក្របខ័ណ្ឌច្បាប់ ........ ២

**២** ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ ........ ៣

២.១ ការស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ ........ ៣

២.២ ការជួសជុល-ថែទាំសំណង់សិល្បការ ........ ៣

២.៣ ការជួសជុល-ថែទាំប្រព័ន្ធធារាសាស្ត្រដោយមានប្រជាពលរដ្ឋចូលរួម ........ ៤

២.៣.១ ការជួសជុល-ថែទាំទំនប់ ........ ៤

២.៣.២ ការជីក-ស្តារប្រឡាយ ........ ៤

២.៤ ការដំឡើង-ជួសជុលស្ថានីយបូមទឹក និងម៉ាស៊ីនបូមទឹក........ ៤

២.៥ ការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក ........ ៤

**៣** ការគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ និងអន្តរាគមន៍ទប់ទល់នឹងគ្រោះរាំងស្ងួត ........ ៤

៣.១ ការគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់-ទឹកប្រៃ ........ ៤

៣.២ ការគ្រប់គ្រង អាងទន្លេ ........ ៥

៣.៣ ការគ្រប់គ្រង និងអន្តរាគមន៍ទប់ទល់ និងគ្រោះរាំងស្ងួត ........ ៥

**៤** ការរៀបចំមូលដ្ឋានព័ត៌មានជលសាស្ត្រ និងឧតុនិយម........ ៦

៤.១ ការងារជលសាស្ត្រ........ ៦

៤.២ ការងារឧតុនិយម ........ ៦

**៥** ការអភិវឌ្ឍធនធានមនុស្ស ........ ៦

**៦** សន្និដ្ឋាន និងការវាយតម្លៃលើការអភិវឌ្ឍវិស័យធនធានទឹកក្នុងរយៈពេល ៥ឆ្នាំ(២០០៤-២០០៨) ........ ៧

**គ- ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម រយៈពេល ៥ឆ្នាំ (២០០៩-២០១៣)** ........ ៨

**១** ដំណើរការរៀបចំយុទ្ធសាស្ត្រ ........ ៨

**២** ស្ថានភាពវិស័យទឹក-ការវិភាគអំពីស្ថានភាព........ ១១

២.១ ទឹក និងតម្រូវការ ........ ១១

២.២ ក្របខ័ណ្ឌស្ថាប័ន........ ១២

២.៣ បញ្ហាតាមផ្នែក........ ១៣

**៣** បេសកកម្ម យុទ្ធសាស្ត្រការងារសំខាន់ៗ និងគោលដៅ របស់ក្រសួងធនធានទឹក ........ ១៤

៣.១ បេសកកម្ម និងគោលបំណង........ ១៤

៣.២ យុទ្ធសាស្ត្រសំខាន់របស់ក្រសួងធនធានទឹក និងឧតុនិយម ........ ១៥

៣.៣ លក្ខណៈវិនិច្ឆ័យជាអាទិភាព ........ ១៦
៣.៤ គោលដៅសំខាន់៧របស់ក្រសួងធនធានទឹក និងឧតុនិយម ........ ១៦
៣.៥ គោលដៅក្នុងការបង្កើនសមត្ថភាពយេនឌ័រក្នុងវិស័យធនធានទឹក ........ ១៧
**៤** ផែនការសកម្មភាពក្នុងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយម ........ ១៧
៤.១ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក ........ ១៨
៤.២ ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ........ ១៩
៤.៣ ការជំរុញរៀបចំច្បាប់ បញ្ញត្តិ និងនិរន្តរភាពនៃទឹក ........ ២០
៤.៤ ការគ្រប់គ្រងព័ត៌មានធនធានទឹក និងឧតុនិយម ........ ២២
៤.៥ ការកែលំអការគ្រប់គ្រងរដ្ឋបាល និងអភិវឌ្ឍន៍ធនធានមនុស្ស ........ ២៣
**៥** ស្ថានភាពថវិកា ........ ២៣
៥.១ ប្រភពថវិកា ........ ២៣
៥.២ ចំណាយ និងចំណូលថវិកាប្រចាំឆ្នាំ ........ ២៤
៥.៣ តម្រូវការថវិកា ........ ២៤
**ឃ- សេចក្តីសន្និដ្ឋាន** ........ ២៥
**ង- អនុសាសន៍ និងសំណូមពរ** ........ ២៥

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើ
# វិស័យធនធានទឹក និងឧតុនិយម ដើម្បីរួមចំណែកក្នុងការអនុវត្ត
# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (២០០៩-២០១៣)

## ក-សេចក្តីផ្តើម

តាមលក្ខណៈភូមិសាស្ត្រ ព្រះរាជាណាចក្រកម្ពុជាត្រូវបានចាត់ទុកថា ជាប្រទេសមួយសម្បូរទៅដោយធនធានទឹក ទន្លេ ស្ទឹង បឹងបួរ ល្អាងទឹកធម្មជាតិក្រោមដី និងសមុទ្រជាដើម គឺជាប្រភពធនធានទឹកដ៏សំខាន់សម្រាប់បម្រើឱ្យដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដូចជា កសិកម្ម ឧស្សាហកម្ម-សិប្បកម្ម ថាមពលអគ្គិសនី នាវាចរណ៍ វប្បធម៌ ទេសចរណ៍ ការទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅប្រចាំថ្ងៃ។

វិសាលភាពទឹកនៃទន្លេមេគង្គកម្ពុជា ដោយរួមបញ្ចូលទាំងបឹងទន្លេសាប ទន្លេសាប ព្រមទាំងដៃទន្លេនានាទៀត មានតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សា និងទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី ហើយផ្តល់នូវធនធានជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ទឹកលើដីមានចំនួនប្រមាណ ៧៥.០០០ លានម$^{៣}$ ដោយមិនគិតពីបរិមាណទឹកដែលស្ថិតក្នុងតំបន់ផ្ទៃរងទឹកភ្លៀងនៅតំបន់មាត់សមុទ្រ និងទឹកក្រោមដី ដែលមានចំនួនប្រមាណ ១៧.៦០០ លានម$^{៣}$។ បរិមាណទឹកនេះ មានច្រើនជាងមួយរយដងនៃបរិមាណទឹក ដែលបានប្រើប្រាស់នាពេលបច្ចុប្បន្ន។ ក្នុងមួយឆ្នាំជាមធ្យមប្រទេសកម្ពុជាបានទទួលអំណោយផលទឹកភ្លៀងប្រមាណពី ១.៤០០ មម ទៅ ៣.៥០០ មម។ ក្នុងមួយឆ្នាំៗបរិមាណទឹកទន្លេមេគង្គប្រមាណ ៤៧៥.០០០ លានម$^{៣}$ បានហូរកាត់ប្រទេសកម្ពុជាធ្លាក់ចុះទៅក្នុងសមុទ្រចិនភាគខាងត្បូង។

ប្រជាជនកម្ពុជាភាគច្រើនជួបប្រទះនឹងភាពខ្វះខាតទឹកនៅរដូវប្រាំង ព្រមទាំងមានកូនរដូវប្រាំង ដែលតែងតែកើតមានឡើងនៅក្នុងរដូវវស្សា ហើយនៅកន្លែងខ្លះបានជួបប្រទះនូវបរិមាណទឹកលើសពីសេចក្តីត្រូវការ ហើយនៅកន្លែងខ្លះទៀត ប្រឈមទៅនឹងកង្វះខាតទឹកដោយពុំមានហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពគ្រប់គ្រាន់ និងមានសភាពចាស់ទ្រុឌទ្រោម ដែលមានការលំបាកដល់ការរក្សាទឹកទុក ការបែងចែកទឹក និងការផ្តល់ ទឹកសម្រាប់វិស័យកសិកម្ម និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

ប្រភពទឹកក្រោមដីក៏មានសារៈសំខាន់ផងដែរ នៅក្នុងការផ្គត់ផ្គង់ទឹក ការថែរក្សានូវតុល្យភាពទឹក និងជាប្រភពទឹកសាបដ៏សំខាន់សម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ការស្រោចស្រពដំណាំកសិកម្ម ឧស្សាហកម្ម ហើយអាចមានលទ្ធភាពផ្តល់ទឹកបានស្ទើរពេញមួយឆ្នាំ។ បច្ចុប្បន្ន ការបែងចែក និងការកំណត់បរិមាណទឹកក្រោមដី ពុំទាន់មានទិន្នន័យ និងព័ត៌មានច្បាស់លាស់នៅឡើយទេ។

ដើម្បីគ្រប់គ្រងធនធានទឹកឱ្យបានល្អប្រសើរ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើនការវិនិយោគលើការស្តារ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹក ដើម្បីជៀសវាងការប្រើប្រាស់គ្មានសណ្តាប់ធ្នាប់ និងការខូចខាតទៅលើធនធានទាំងនោះ ដែលបង្កភាពអន្តរាយដល់កិច្ចអភិវឌ្ឍយូរអង្វែងរបស់ប្រទេសជាតិ។

ក្នុងការអនុវត្តនូវតួនាទីរបស់ខ្លួននៅក្នុងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងធនធានទឹក និងឧតុនិយម បានប្រមូលផ្តុំ និងប្រើប្រាស់យ៉ាងពេញទំហឹងនូវធនធាននានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិ ដូចជាៈ

-ការស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រ ក្នុងគោលបំណងផ្តល់ទឹកគ្រប់គ្រាន់ដល់ដំណាំកសិកម្ម ការប្រើប្រាស់ទឹកប្រចាំថ្ងៃរបស់ប្រជាជន និងសត្វពាហណៈ ព្រមទាំងទេសចរណ៍។

-ទំនប់ការពារទប់ស្កាត់ទឹកជំនន់ និងទំនប់ការពារទប់ស្កាត់ទឹកប្រៃក្នុងគោលដៅការពារផ្ទៃដីកសិកម្ម និងការពារទ្រព្យសម្បត្តិសាធារណៈ។

ដើម្បីសម្រេចបាននូវកិច្ចប្រឹងប្រែងនេះ ទាមទារនូវការគាំទ្រទាំងផ្នែកថវិកា និងបច្ចេកទេសពីរាជរដ្ឋាភិបាល ការចូលរួមពីវិស័យឯកជន និងសហគមន៍ផ្តល់ជំនួយ។ ក្នុងពេលអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលរយៈពេល ៥ឆ្នាំ (២០០៤-២០០៨) កន្លងមក និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ (ពាក់កណ្តាលអាណត្តិ) មានដៃគូអភិវឌ្ឍន៍ជាច្រើនចូលរួមក្នុងវិស័យធនធានទឹកទឹកដូចជា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ អង្គការស្បៀងអាហារ និងកសិកម្ម ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម ប្រទេសជប៉ុន ប្រទេសបារាំង ប្រទេសឥណ្ឌា ប្រទេសចិន ប្រទេសកូរ៉េ ។ល។ ការចូលរួមដ៏មានតម្លៃនេះ អាចគាំទ្រដល់ដំណើរការគ្រប់គ្រង និងអភិវឌ្ឍធនធានទឹក ដើម្បីសម្រេចបានគោលដៅក្នុងការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ដល់កសិកម្ម ព្រមទាំងចូលរួមចំណែកដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ។

ក្រសួងធនធានទឹក និងឧតុនិយម បានសិក្សា និងវាយតម្លៃយ៉ាងល្អិតល្អន់នូវការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ (ពាក់កណ្តាលអាណត្តិ) កន្លងមក និងសមិទ្ធផលដែលក្រសួងសម្រេចបានលើការគ្រប់គ្រង និងការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយមក្នុងរយៈពេល ៥ឆ្នាំ ២០០៤-២០០៨ បានយ៉ាងច្រើនគួរជាទីមោទនៈ។

## ២. វឌ្ឍនភាពនៃការអនុវត្តវិស័យធនធានទឹក និងឧតុនិយមរយៈពេល ៥ឆ្នាំ ២០០៤-២០០៨

ក្រសួងមានតួនាទី និងកាតព្វកិច្ចយ៉ាងសំខាន់ក្នុងការតាមដាន និងគ្រប់គ្រងនូវរាល់សកម្មភាពពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានទឹក និងឧតុនិយម ព្រមទាំងកាត់បន្ថយគ្រោះមហន្តរាយធម្មជាតិ។ ដូច្នេះការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងនិងការអភិវឌ្ឍធនធានទឹករបស់ក្រសួង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៣នៃរដ្ឋសភា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ (ពាក់កណ្តាលអាណត្តិ) កន្លងមកក្នុងការធ្វើឱ្យកើនឡើងនូវលទ្ធភាព និងសក្តានុពលស្រោចស្រព បន្ថែមលើលទ្ធភាពដែលមានកន្លងមក ដើម្បីបង្កើនផលិតផលកសិកម្មព្រមទាំងការកាត់បន្ថយទឹកជំនន់ គ្រោះរាំងស្ងួត និងការពារទឹកប្រៃនោះ ក្រសួងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព។ ជាក់ស្តែងសមិទ្ធផលដែលសម្រេចបានមានដូចខាងក្រោមៈ

### ១.ការរៀបចំក្របខ័ណ្ឌច្បាប់

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ច្បាប់ពាក់ព័ន្ធនឹងទឹក បញ្ញត្តិនៃច្បាប់ និងគោល

នយោបាយស្តីពីការគ្រប់គ្រងធនធានទឹក ដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រងរាល់គម្រោងអភិវឌ្ឍន៍ធនធានទឹក ព្រមទាំងធានានូវនិរន្តរភាព។ **ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា** ត្រូវបានព្រះករុណាឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើនៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ បន្ទាប់ពីរដ្ឋសភាប្រជុំអនុម័តនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧ និងព្រឹទ្ធសភាប្រជុំអនុម័តនៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៧។

គោលនយោបាយជាតិ លើវិស័យធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏បានអនុម័តឱ្យប្រើប្រាស់ជាផ្លូវការនាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៤។

យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ២០០៦-២០១០ ត្រូវបានរៀបចំឡើង និងបានចុះហត្ថលេខាដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៧ បានចូលរួមក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២របស់រាជរដ្ឋាភិបាល ពិសេសជួយសម្របសម្រួលថវិកាឥណទាន ឬហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ផងដែរ។

## ២-ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ :

### ២.១-ការស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ :

ប្រទេសកម្ពុជា ជាប្រទេសសំបូរទៅដោយធនធានទឹក និងប្រព័ន្ធទន្លេ ដូចជា ទន្លេមេគង្គ បឹងទន្លេសាប ទន្លេសាប និងដៃទន្លេនានា តែផ្ទៃដីទទួលការស្រោចស្រពនៅមានកម្រិតនៅឡើយ។ ក្រសួងធនធានទឹក និងឧតុនិយម បានជួសជុល-ស្តារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រចំនួន ១៤១គម្រោង មានលទ្ធភាពស្រោចស្រពលើផ្ទៃដីកសិកម្មសរុបចំនួន ២៦៧.២២៤ហិកតា (ស្រូវវស្សាចំនួន ១៩១.២០២ហិកតា និងស្រូវប្រាំងចំនួន ៧៦.០២២ហិកតា) ដោយប្រើប្រាស់ថវិកាសរុបចំនួន ១៦៣.២០៩.១៤៣.៦៣៨ រៀល និង ២២.៧១១.៦៨៣,៦ ដុល្លារអាមេរិក។ លទ្ធផលខាងលើមានតាមបណ្តាឆ្នាំដូចខាងក្រោម :

| បរិយាយ | ឯកតា | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | សរុប |
|---|---|---|---|---|---|---|---|
| គម្រោង | ចំនួន | ៣០ | ២៣ | ៣៩ | ១៨ | ៣១ | ១៤១ |
| ផ្ទៃដីស្រូវវស្សា | ហិកតា | ១៦,២២៣ | ៣៧,២៧៦ | ៧៥,១០១ | ៣៧,១០៩ | ២៥,៤៩៣ | ១៩១,២០២ |
| ផ្ទៃដីស្រូវប្រាំង | ហិកតា | ១១,៨២៥ | ៦,៥៧០ | ១៤,១១០ | ១៤,៩៥៧ | ២៨,៥៦០ | ៧៦,០២២ |
| សរុបផ្ទៃដី | ហិកតា | ២៨,០៤៨ | ៤៣,៨៤៦ | ៨៩,២១១ | ៥២,០៦៦ | ៥៤,០៥៣ | ២៦៧,២២៤ |
| ទឹកប្រាក់ | រៀល | ៣,៥០៣,៩៦២,០០០ | ១៧,៩៨៥,០០០,០០០ | ៣៨,៤៦៦,១៧៧,១៩៨ | ៣២,៧១៤,០០៨,៤៤០ | ៧០,៥៤០,០០០,០០០ | ១៦៣,២០៩,១៤៣,៦៣៨ |
| ទឹកប្រាក់ | ដុល្លារ | ៤,៣៤០,៥៤៤.៨ | ៣៦៧,៦០៥ | ៦៤៦,៨៧០ | ១៧,២៨៦,៦៦៤.៨ | ៦៩,៩៩៩ | ២២,៧១១,៦៨៣.៦ |

### ២.២-ការជួសជុល-ថែទាំសំណង់សិល្បការ :

ក្រសួងបានធ្វើការជួសជុល-ថែទាំ សំណង់សិល្បការតាមបណ្តាប្រព័ន្ធធារាសាស្ត្រនៅតាមខេត្តហើយសម្រេចបានរួមមាន សំណង់ទ្វារទឹកសរុបចំនួន ២៧០កន្លែង សំណង់លូទឹកសរុបចំនួន ៣៧៧កន្លែង សំណង់ស្នាក់ទឹកសរុបចំនួន ៩០កន្លែង និងសំណង់បង្ហៀរទឹកសរុបចំនួន ២៩កន្លែងដោយចំណាយថវិកាសរុបចំនួន ១.២៦៦.១២៨.៣៧៧រៀល និង ៨៤១.៦៥៥,២១ដុល្លារ។

## ២.៣-ការជួសជុល-ថែទាំប្រព័ន្ធធារាសាស្ត្រដោយមានប្រជាពលរដ្ឋចូលរួម :

### ២.៣.១-ការជួសជុល-ថែទាំទំនប់ :

បានធ្វើការជួសជុលថែទាំទំនប់នៅតាមបណ្តាខេត្តសរុបចំនួន ៧៩៤កន្លែង ប្រវែង ៣៧៦.៧៨៧ម សាច់ដីសរុបចំនួន ១.៩៧២.៧៦៦ម៣ ប្រជាពលរដ្ឋចូលរួម ២៤.៨៨២នាក់ និងគ្រឿងចក្រ។ លទ្ធផលខាងលើនេះបានប្រើប្រាស់អង្ករសរុបចំនួន ៩២៩.៧៣០គ.ក្រ សំបកបាវសរុបចំនួន ២៩៩.១១៥សំបក ប្រេងម៉ាស៊ូតចំនួន ៣៩៣.០១០លីត្រ ថវិកាចំនួន ២.០៨៩.៩៧០.២១៣រៀល និង ២៦៩.៤៦៤,៤ដុល្លារ។

### ២.៣.២-ការជីក-ស្តារប្រឡាយ :

បានធ្វើការជីក-ស្តារប្រឡាយនៅតាមបណ្តាខេត្តសរុបចំនួន ១.២៦៦ខ្សែ ប្រវែង ២.២៥៥.៧៩៣ម សាច់ដីសរុបចំនួន ៥.២០៩.៧៨១ម៣ ប្រជាពលរដ្ឋចូលរួម ២៩.៦២០នាក់ និងគ្រឿងចក្រ។ លទ្ធផលខាងលើនេះបានប្រើប្រាស់អង្ករសរុបចំនួន ៥.៨៧០.៥៤៤គ.ក្រ ប្រេងម៉ាស៊ូតចំនួន ១.១៤២.២០០លីត្រ ថវិកាចំនួន ៣.៦១៨.២២៦.០៨៦រៀល និង ១.៩៦០.៧៨៩,៣២ដុល្លារ។

## ២.៤-ការដំឡើង ជួសជុលស្ថានីយបូមទឹក និងម៉ាស៊ីនបូមទឹក:

ដំឡើងស្ថានីយបូមទឹកចំនួន ១២ស្ថានីយ និងជួសជុលស្ថានីយ ១កន្លែង ដោយចំណាយថវិកាសចំនួន ២២.០០០ដុល្លារ និង៤៨.០៩៤.០៨០រៀល ហើយបានជួសជុលម៉ាស៊ីនបូមទឹកចំនួន ៧៨គ្រឿង និងទិញម៉ាស៊ីនបូមទឹកធុនមធ្យមចំនួន ១៨០គ្រឿង ជាឥណទានរបស់ប្រទេសឥណ្ឌាមានចំនួន ៥.២០០.០០០ដុល្លារ ។

## ២.៥-ការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក :

ក្រសួងបានរៀបចំសហគមន៍កសិករប្រើប្រាស់ទឹកនៅតាមប្រព័ន្ធធារាសាស្ត្រក្នុងរយៈពេល ៥ឆ្នាំ (២០០៤-២០០៨) បានចំនួន ៣៥០សហគមន៍ ក្នុងនោះមានផ្ទៃដីស្រូវរដូវវស្សាសរុបចំនួន ២៤៥.១២២,៥ហ.ត ផ្ទៃដីស្រូវរដូវប្រាំងសរុបចំនួន ១០៥.១៥៧,៥ហ.ត និងមានប្រជាពលរដ្ឋចំនួន ៣០៥.៥៥០គ្រួសារ ក្នុងនោះស្ត្រីក៏បានចូលរួមយ៉ាងសកម្មផងដែរនៅក្នុងជួរថ្នាក់ដឹកនាំគណកម្មាធិការសហគមន៍។

## ៣-ការគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ និងអន្តរាគមន៍ទប់ទល់នឹងគ្រោះរាំងស្ងួត :

### ៣.១- ការគ្រប់គ្រងអាងទន្លេ :

ក្រសួងធនធានទឹក និងឧតុនិយមបានធ្វើការសិក្សាអាងទន្លេ-ស្ទឹងនៅជុំវិញបឹងទន្លេសាប និងស្ទឹងសំខាន់ៗមួយចំនួនទៀត ដើម្បីធ្វើការគ្រប់គ្រង និងអភិរក្សវិស័យធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជាឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព ដូចជា អាងស្ទឹងបរិបូរណ៍ អាងស្ទឹងដូនទ្រី អាងស្ទឹងមង្គលបូរី អាងស្ទឹងសង្កែ អាងស្ទឹងស្វាយចេក អាងស្ទឹងព្រែកត្នោត និងស្ទឹងក្រាំងពន្លៃ។ ទន្ទឹមនឹងនេះក្រសួងធនធានទឹក និងឧតុនិយមក៏បានរៀបចំផែនការមេ ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៣.២_ ការគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់_ទឹកប្រៃ :

ទឹកជំនន់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ បានបណ្តាលឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធ រូបវ័ន្ត និងសេដ្ឋកិច្ចសង្គមជាច្រើន។ ក្រសួងធនធានទឹក និងឧតុនិយមបានធ្វើការជួសជុលទំនប់ទប់ស្កាត់ទឹកជំនន់ និងទឹកប្រៃដូចមានខាងក្រោម :

-ជួសជុលទំនប់ការពារទប់ស្កាត់ទឹកជំនន់បានចំនួន ៧គម្រោង ដែលមានលទ្ធភាពការពារលើផ្ទៃដីដាំដុះបានចំនួន ១៣០.៧៩៩ហ.ត ចំណាយថវិកាសរុបចំនួន ២២.៧៦៥.៣៣០.១០០រៀល និង ២.៤៥២.០១៥ដុល្លារ។

-ជួសជុលទំនប់ការពារទប់ស្កាត់ទឹកប្រៃបានចំនួន ៦គម្រោង ដែលមានលទ្ធភាពការពារលើផ្ទៃដីដាំដុះបានចំនួន ១៤.៣២៨ហ.ត ចំណាយថវិកាសរុបចំនួន ១.៤៨៤.១៨៩.៩០០រៀល និង ៤៣៨.០៦៤ដុល្លារ។

ក្រៅពីនេះការកែលំអការហូរច្រោះ និងបាក់ច្រាំងទន្លេត្រូវបានចាត់ទុកថា ជាបញ្ហាយ៉ាងសំខាន់ដែលទាមទារឱ្យមានវិធានការជាបន្ទាន់។ ក្រសួងបានជួសជុលច្រាំងបាក់នៅក្រុងក្រចេះប្រវែងសរុប ១២៨ម ដោយប្រើប្រាស់ថវិការដ្ឋ។ បានសិក្សា និងលើកគម្រោងច្រាំងទន្លេមេគង្គត្រង់ចំណុចស្ថានីយជលសាស្ត្រក្រុងកំពង់ចាម សិក្សាច្រាំងទន្លេមេគង្គនៅតំបន់កោះប្រាក់ សិក្សាច្រាំងបាក់ទន្លេមេគង្គនៅតំបន់វត្តគៀនឃ្លាំង (ព្រែកលៀប) ទៅដល់ស្រុកមុខកំពូល ខេត្តកណ្តាល និងសិក្សាស្ថានភាពបាតទន្លេបាសាក់នៅត្រង់ភូមិសាស្ត្រចាក់អង្រែ។

## ៣.៣_ការគ្រប់គ្រង និងការអន្តរាគមន៍ទប់ទល់នឹងគ្រោះរាំងស្ងួត :

គ្រោះរាំងស្ងួតតែងកើតមានឡើង និងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលិតផលកសិកម្ម ដែលជាហេតុបណ្តាលឱ្យទិន្នផលស្រូវធ្លាក់ចុះ ធ្វើឱ្យប្រជាកសិករមានចំណូលទាប។ ក្នុងន័យនេះ ការអន្តរាគមន៍ដោយម៉ាស៊ីនបូមទឹក ដែលជួយដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើរតួយ៉ាងសំខាន់ក្នុងការសង្គ្រោះ បន្ធូរបន្ថយ និងកែលំអដំណាំកសិកម្ម ដែលប៉ះពាល់ពីគ្រោះរាំងស្ងួត។

ក្រសួងធនធានទឹក និងឧតុនិយម បានប្រមូលផ្តុំនូវម៉ាស៊ីនបូមទឹក និងមធ្យោបាយចាំបាច់នានា ដើម្បីសង្គ្រោះស្រូវដែលប៉ះពាល់ពីគ្រោះរាំងស្ងួតដោយសម្រេចបានលើផ្ទៃដីសរុបចំនួន ៦២៥.៣៤៩ហិកតា ក្នុងនោះស្រូវប្រាំងសរុបចំនួន ២៣២.៩៥៥ហិកតា និងស្រូវវស្សាចំនួន ៣៩២.៣៩៤ហិកតា ដោយប្រើប្រាស់ប្រេងម៉ាស៊ូតចំនួន ៨.៧៣៥.០៤២លីត្រ និងប្រេងរំអិលចំនួន ៥៦.៦៤៧លីត្រ។ លទ្ធផលខាងលើមានតាមបណ្តាឆ្នាំដូចក្នុងតារាងខាងក្រោម :

| **បរិយាយ** | **ឯកតា** | **២០០៤** | **២០០៥** | **២០០៦** | **២០០៧** | **២០០៨** | **សរុប** |
|---|---|---|---|---|---|---|---|
| ស្រូវប្រាំង | ហ.ត | ៤៧.១៧៦ | ៤៨.៦៧៥ | ៤៤.៩៨៩ | ៤៥.៤៣៤ | ៤៦.៦៩៩ | **២៣២.៩៥៥** |
| ស្រូវវស្សា | ហ.ត | ១៤៤.៤២០ | ៧៩.៨៧១ | ៧៥.០០៣ | ៥០.២០៣ | ៤២.៨៩៧ | **៣៩២.៣៩៤** |
| សរុប | ហ.ត | **១៩១.៥៩៦** | **១២៨.៥២៨** | **១១៩.៩៩២** | **៩៥.៦៣៧** | **៨៩.៥៩៦** | **៦២៥.៣៤៩** |
| ប្រេងម៉ាស៊ូត | លីត្រ | ២.៥៣៧.៨០០ | ១.៧៨៥.៧១០ | ១.៧៤៦.២៤០ | ១.៣៨៦.៥៩២ | ១.២៧៨.៧០០ | **៨.៧៣៥.០៤២** |
| ប្រេងម៉ាស៊ីន | លីត្រ | ៩.៧៣៧ | ១០.៣០០ | ១៤.០០០ | ១១.៤០០ | ១១.២១០ | **៥៦.៦៤៧** |

ក្រៅពីការងារអន្តរាគមន៍សង្គ្រោះស្រូវដោយម៉ាស៊ីនបូមទឹក ក៏មានការងារសង្គ្រោះស្រូវដោយប្រព័ន្ធធារាសាស្ត្រ (បង្ហូរ) ហើយសម្រេចបានលទ្ធផលសរុបចំនួន ២១៩.២១១ហ.ត ក្នុងនោះស្រូវរដូវប្រាំងចំនួន ៨៧.៥១០ហិកតា និងស្រូវរដូវវស្សាចំនួន ១៣១.៧០១ហិកតា។ លទ្ធផលខាងលើមានតាមបណ្តាឆ្នាំដូចក្នុងតារាងខាងក្រោម :

| **បរិយាយ** | **ឯកតា** | **២០០៤** | **២០០៥** | **២០០៦** | **២០០៧** | **២០០៨** | **សរុប** |
|---|---|---|---|---|---|---|---|
| ស្រូវប្រាំង | ហ.ត | ២៧.០២២ | ៧..៦១១ | ២០.១៣៥ | ១៦.២៥១ | ១៦.៤៩១ | **៨៧.៥១០** |
| ស្រូវវស្សា | ហ.ត | ៦៣.០៧៣ | ២៧.៧០៥ | ៣.៨៩៧ | ៣.៨៤៦ | ៣៣.១៨០ | **១៣១.៧០១** |
| **សរុប** | ហ.ត | **៩០.០៩៥** | **៣៥.៣១៦** | **២៤.០៣២** | **២០.០៩៧** | **៤៩.៦៧១** | **២១៩.២១១** |

## ៤-ការរៀបចំមូលដ្ឋានព័ត៌មានជលសាស្ត្រ និងឧតុនិយម

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ គ្រោះរាំងស្ងួត និងទឹកជំនន់ ដែលជាគ្រោះធម្មជាតិដ៏ធំ បានធ្វើឱ្យបាត់បង់ដល់អាយុជីវិតមនុស្ស សត្វ ខូចខាតទ្រព្យសម្បត្តិសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជាច្រើន។ ដើម្បីទប់ទល់នឹងគ្រោះមហន្តរាយធម្មជាតិនេះ ទាមទារឱ្យមានការដំឡើងប្រព័ន្ធព្យាករណ៍ជលសាស្ត្រ និងឧតុនិយមសម្រាប់ជូនដំណឹងជាមុនឱ្យទាន់ពេលវេលា ជូនដល់សាធារណជន។ សមិទ្ធផលការងារខាងលើដែលសម្រេចបានមានៈ

### ៤.១-ការងារជលសាស្ត្រ

-ជួសជុល និងដំឡើងស្ថានីយជលសាស្ត្រចំនួន ២០កន្លែង នៅតាមបណ្តោយទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់។

-ដំឡើងក្តារវាស់កម្ពស់ទឹកចំនួន ៣៩កន្លែង នៅតាមចំណុចត្រួតពិនិត្យតាមបណ្តោយទន្លេ និងស្ទឹងសំខាន់ៗ។

-ដំឡើងម៉ាស៊ីនកត់ត្រាកម្ពស់ទឹកដោយស្វ័យប្រវត្តិចំនួន ១៣កន្លែង នៅតាមចំណុចត្រួតពិនិត្យតាមបណ្តោយទន្លេ និងស្ទឹងសំខាន់ៗ។

-ដំឡើងឧបករណ៍វាស់ធារទឹកបាន ៤កន្លែង នៅស្ទឹងសៀមរាប ខេត្តសៀមរាប ស្ទឹងសង្កែ ខេត្តបាត់ដំបង ស្ទឹងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ស្ទឹងបរិបូរ ខេត្តកំពង់ឆ្នាំង។

### ៤.២-ការងារឧតុនិយម

-ជួសជុលកែលំអ ស្ថានីយពិនិត្យសង្កេតធាតុអាកាស នៅតាមបណ្តារាជធានី-ខេត្តសរុបចំនួន ៨កន្លែង។

-ដំឡើងស្ថានីយពិនិត្យសង្កេតធាតុអាកាសថ្មី នៅតាមបណ្តាខេត្តបានចំនួន ៥កន្លែង។

-ដំឡើងស្ថានីយសម្រាប់វាស់ទិស-ល្បឿនខ្យល់រយៈកម្ពស់ ១០-១០០ម៉ែត្រ ពិនិត្យសង្កេតកំដៅ និងពន្លឺព្រះអាទិត្យ នៅតាមបណ្តារាជធានី-ខេត្តសរុបចំនួន ៥កន្លែង។

-ដំឡើងស្ថានីយទទួលព័ត៌មានតាមរយៈផ្កាយរណប ដើម្បីពិនិត្យស្ថានភាពពពកនៅរយៈកម្ពស់ MTSAT ចំនួន ១កន្លែង។

-ដំឡើងប្រព័ន្ធទូរគមនាគមន៍ ទទួល និងបញ្ជូនទិន្នន័យឧតុនិយមក្របខ័ណ្ឌជាតិ និងអន្តរជាតិ GTS ចំនួន ១កន្លែង។

## ៥-ការអភិវឌ្ឍធនធានមនុស្ស

ក្រសួងធនធានទឹក និងឧតុនិយម និងដៃគូអភិវឌ្ឍន៍បានរៀបចំសិក្ខាសាលា និងបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីគ្រប់លំដាប់ថ្នាក់នូវមុខវិជ្ជាពាក់ព័ន្ធដល់កិច្ចអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយម ដោយមានការយកចិត្តទុកដាក់ និងលើកទឹកចិត្តដល់មន្ត្រីជាស្ត្រីឱ្យចូលរួមផងដែរ ហើយសម្រេចបានលទ្ធផលដូចខាងក្រោម :

| ល.រ | បរិយាយ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | សរុប |
|---|---|---|---|---|---|---|---|
| ១ | **បណ្តុះបណ្តាល** | | | | | | |
| | -ក្នុងប្រទេស | ២១១នាក់ | ២០៥នាក់ | ២៦៧នាក់ | ២៨១នាក់ | ២២៦នាក់ | **១.១៩០នាក់** |
| | -ក្រៅប្រទេស | ១៤នាក់ | ២៧នាក់ | ៣៤នាក់ | ៣៩នាក់ | ៣២នាក់ | **១៤៦នាក់** |
| | **សរុប** | **២២៥នាក់** | **២៣២នាក់** | **៣០១នាក់** | **៣២០នាក់** | **២៥៨នាក់** | **១.៣៣៦នាក់** |
| ២ | **សិក្ខាសាលា** | | | | | | |
| | -ក្នុងប្រទេស | ១០២នាក់ | ១៩៣នាក់ | ២២៧នាក់ | ២០៩នាក់ | ១៤៦នាក់ | **៨៧៧នាក់** |
| | -ក្រៅប្រទេស | ៤០នាក់ | ៤៤នាក់ | ៣៣នាក់ | ២៩នាក់ | ៣៨នាក់ | **១៨៤នាក់** |
| | **សរុប** | **១៤២នាក់** | **២៣៧នាក់** | **២៦០នាក់** | **២៣៨នាក់** | **១៨៤នាក់** | **១.០៦១នាក់** |

## ៦_សន្និដ្ឋាន និងវាយតម្លៃលើការអភិវឌ្ឍវិស័យធនធានទឹកក្នុងរយៈពេល ៥ឆ្នាំ(២០០៤_២០០៨)

ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ២០០៤-២០០៨ ក្នុងនីតិកាលទី៣នៃរដ្ឋសភាជាតិ កន្លងមក ដើម្បីបង្កើនសេដ្ឋកិច្ច សំដៅឈានទៅអភិវឌ្ឍសង្គម ពិសេសការកាត់បន្ថយភាពក្រីក្រជាជំហ៊ានៗនោះ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិពាក់កណ្តាលអណត្តិ ក្រសួងធនធានទឹក និងឧតុនិយម បានកំណត់នូវគោលនយោបាយក្នុងការបង្កើនលទ្ធភាពស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រឱ្យបានចំនួន ២០.០០០ហ.ត ក្នុងមួយឆ្នាំបន្ថែមលើលទ្ធភាពដែលមានកន្លងមកតាមរយៈការប្រមូលទឹកទុកនារដូវវស្សាឱ្យបានច្រើន ដើម្បីឈានទៅធ្វើស្រែពីរដងក្នុងមួយឆ្នាំ សម្រាប់បង្កើនចំណូលក៏ដូចជាបង្កើនការងារជូនប្រជាកសិករ។ ជាក់ស្តែងរយៈពេល ៥ឆ្នាំ ២០០៤-២០០៨ **ក្រសួងសម្រេចបាននូវការបង្កើន :**

-លទ្ធភាពស្រោចស្រពលើផ្ទៃដីសរុបចំនួន ២៦៧.២២៤ហ.ត បន្ថែមលើលទ្ធភាពស្រោចស្រពដែលមានស្រាប់ នៅចុងឆ្នាំ ២០០៣ ចំនួន ៥៦០.១៤៩ហ.ត។

-លទ្ធភាពការពារទប់ស្កាត់ទឹកជំនន់លើផ្ទៃដីសរុបចំនួន ១៣០.៧៩៩ហ.ត បន្ថែមលើលទ្ធភាពការពារដែលមានស្រាប់ នៅចុងឆ្នាំ ២០០៣ ចំនួន ១១៣.៥០០ហ.ត។

-លទ្ធភាពការពារទប់ស្កាត់ទឹកប្រៃលើផ្ទៃដីសរុបចំនួន ១៤.៣២៨ហ.ត បន្ថែមលើលទ្ធភាពការពារដែលមានស្រាប់ នៅចុងឆ្នាំ ២០០៣ ចំនួន ១៦.៦៨០ហ.ត។

សរុបមកវិញគិតដល់ឆ្នាំ ២០០៨ ក្នុងក្របខ័ណ្ឌទូទាំងប្រទេសយើងមានលទ្ធភាពស្រោចស្រពពេញលេញ និងបំពេញបន្ថែមដោយប្រព័ន្ធធារាសាស្ត្របានចំនួន **៨២៧.៣៧៣ហ.ត** ស្មើនឹង ៣១,៦៣% បើប្រៀបធៀបទៅនឹងផ្ទៃដីបង្កបង្កើនផលស្រូវចំនួន ២.៦១៥.៧៤១ហ.ត ( ស្រង់ពីរបាយការណ៍បូកសរុបសន្និបាតកសិកម្មនាថ្ងៃទី ០៧-០៩ ខែ មេសា ឆ្នាំ ២០០៩) ក្នុងនោះលទ្ធភាពស្រោចស្រព សម្រាប់ស្រូវរដូវវស្សា ៥៨២.០៨៥ហ.ត និងសម្រាប់ស្រូវរដូវប្រាំង ២៤៥.២៨៨ហ.ត ប៉ុន្តែ **សក្តានុពលលទ្ធភាពស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រទាំងអស់មានរហូតដល់ ១.១២០.២៤៦ហ.ត ( រដូវវស្សា ៧៧៣.១៨៨ ហ.ត និងរដូវប្រាំង ៣៤៧.០៥៨ ហ.ត) តាមការសិក្សា និងស្រង់ទិន្នន័យប្រភពទឹក និងអាងស្តុកទឹក**។ លទ្ធភាពការពារទប់ស្កាត់ទឹកជំនន់លើផ្ទៃដីសរុបចំនួន ២៤៤.២៩៩ហ.ត និងលទ្ធភាពការពារទប់ស្កាត់ទឹកប្រៃលើផ្ទៃដីសរុប

ចំនួន ៣១.០០៨ហ.ត ។ កំណើនលទ្ធភាពស្រោចស្រព និងលទ្ធភាពការពារខាងលើនេះ គឺដោយមានការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងធនធានទឹក និងឧតុនិយម ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដៃគូអភិវឌ្ឍន៍ និងក្រសួងពាក់ព័ន្ធនានា ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## គ.ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយមរយៈពេល ៥ឆ្នាំ(២០០៩-២០១៣)

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម បង្ហាញអំពីគោលដៅ គោលបំណង និងសកម្មភាពនានារបស់ក្រសួងធនធានទឹក និងឧតុនិយមក្នុងឆ្នាំ ២០០៩-២០១៣ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍នេះផ្តល់នូវទិន្នន័យដើម្បីបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។ ក្រសួងធនធានទឹក និងឧតុនិយម មានភារកិច្ចទទួលខុសត្រូវរាល់ទិដ្ឋភាពទាំងអស់នៃធនធានទឹករបស់ជាតិ ដើម្បីធានាឱ្យមាននិរន្តរភាពសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមដែលទាក់ទងនឹងវិស័យទឹក ដូចជា ការផ្គត់ផ្គង់ទឹកសម្រាប់វិស័យកសិកម្ម ការផ្គត់ផ្គង់ទឹកនៅទីក្រុង និងជនបទ វារីអគ្គិសនី ការនេសាទ គមនាគមន៍ និងទេសចរជាដើម ។

វិស័យធនធានទឹក និងឧតុនិយម គឺជាវិស័យមួយដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងគោលនយោបាយជាតិស្តីពីការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ការអភិវឌ្ឍវិស័យធនធានទឹក នឹងអាចជួយកាត់បន្ថយនូវគ្រោះមហន្តរាយដែលកើតឡើងពីធម្មជាតិ និងធានាដល់ការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់សម្រាប់ការបង្កបង្កើនផលស្រូវ ដំណាំគ្រប់ប្រភេទ (ជួយលើកស្ទួយដល់សន្តិសុខស្បៀងប្រកបដោយប្រសិទ្ធិភាព) ព្រមទាំងជួយបង្កើនលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋរស់នៅតាមទីក្រុង និងតាមជនបទ ជាពិសេសដល់ស្ត្រី និងកុមារ ។

**ទឹក** គឺជាមូលដ្ឋានគ្រឹះសម្រាប់កិច្ចអភិវឌ្ឍលើគ្រប់វិស័យនៃសេដ្ឋកិច្ចជាតិ។ ដោយផ្អែកលើអត្ថប្រយោជន៍នៃទឹកចំពោះការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម ក្រសួងធនធានទឹក និងឧតុនិយម រៀបចំផែនការយុទ្ធសាស្ត្រ និងសកម្មភាពស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក និងឧតុនិយម ២០០៩-២០១៣ ដើម្បីមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និងយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី២ (២០០៩-២០១៣) ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា និងដើម្បីជំរុញសមត្ថភាពក្រសួង-ស្ថាប័នពិសេសអំពីច្បាប់ ក្របខ័ណ្ឌនៃការគ្រប់គ្រងការងារ ការគ្រប់គ្រងធនធានមនុស្ស និងការគ្រប់គ្រងព័ត៌មានជាដើមសម្រាប់នីតិកាលទី៤នៃរដ្ឋសភា ២០០៨-២០១៣ ក្នុងគោលបំណងសម្រេចឱ្យបានគោលដៅចំបងនៃការកាត់បន្ថយភាពក្រីក្រ ។

### ១.ដំណើរការរៀបចំយុទ្ធសាស្ត្រ

ឯកសារដែលជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម គឺ (១) យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី២ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា (២) អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម និង (៣) គោលនយោបាយជាតិលើវិស័យធនធានទឹកនៅកម្ពុជា។

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើ វិស័យធនធានទឹក និងឧតុនិយម**

| យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល | អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម | គោលនយោបាយជាតិលើវិស័យធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជា | របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០០៨ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
|---|---|---|---|
| មូលដ្ឋានគ្រឹះទី១ | មូលដ្ឋានគ្រឹះទី២ | មូលដ្ឋានគ្រឹះទី៣ | |

**១.១-មូលដ្ឋានគ្រឹះទី១ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដំណាក់កាលទី២**

**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** ត្រូវបាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសជាផ្លូវការក្នុងសម័យប្រជុំលើកទី១ នៃគណៈរដ្ឋមន្ត្រីសម្រាប់នីតិកាលទី៤ នៃរដ្ឋសភា នាថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី គឺបន្តពី **យុទ្ធសាស្ត្រចតុកោណ** ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នឹងត្រូវបានដាក់ប្រើប្រាស់ជាឧបករណ៍យ៉ាងសំខាន់សម្រាប់គាំទ្រដល់ការ អនុវត្ត **"កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤ នៃរដ្ឋសភា"**។ ក្រសួងធនធានទឹក និងឧតុនិយម បានផ្អែកលើយុទ្ធសាស្ត្រដែលបានរៀបរាប់ខាងលើរួចមកហើយនេះ ធ្វើជាមូលដ្ឋានគ្រឹះក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងសកម្មភាពសម្រាប់កិច្ចអភិវឌ្ឍន៍ និងការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាព ហើយខ្លឹមសារនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនេះត្រូវបានកំណត់ដូចខាងក្រោម :

(១) ការលើកស្ទួយវិស័យកសិកម្ម

(២) ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

(៣) ការអភិវឌ្ឍផ្នែកឯកជន និងការងារ

(៤) ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស

យុទ្ធសាស្ត្រខាងលើនេះបានបញ្ជាក់យ៉ាងច្បាស់អំពីគោលដៅជាអាទិភាពរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយការអភិវឌ្ឍន៍យុទ្ធសាស្ត្រនៃការគ្រប់គ្រងធនធានទឹក ដែលជាការទទួលខុសត្រូវរបស់ក្រសួងធនធានទឹក និងឧតុនិយម គឺជាការរួមចំណែកមួយនៃយុទ្ធសាស្ត្រចតុកោណ។

មានចតុកោណបួននៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ជ្រុងមួយ ឬពីរនៃចតុកោណនីមួយៗមានយុទ្ធសាស្ត្រសំខាន់ៗរបស់ក្រសួងធនធានទឹក និងឧតុនិយមសម្រាប់ឆ្នាំ ២០០៩-២០១៣:

+ចតុកោណទី ១: ការលើកស្ទួយវិស័យកសិកម្ម

- ជ្រុងទី ១: ការលើកកម្ពស់ផលិតភាព និងពិពិធកម្មវិស័យកសិកម្ម [២]

**២** យុទ្ធសាស្ត្រចតុកោណបានថែងថា ការបង្វែរទិសពីការអភិវឌ្ឍន៍តាមបែប" បើកទូលាយ" ឬតាមបែប វិបុលកម្ម" ទៅកាន់ការអភិវឌ្ឍន៍តាមបែប ស៊ីជម្រៅ ឬតាមបែប ប្រពលកម្ម" ពោលគឺការពង្រឹងសមត្ថភាពចិញ្ចឹមលើផ្ទៃដីដែលមានស្រាប់តាមរយៈប្រពលកម្ម បានក្លាយទៅជាអាទិភាពដ៏ខ្ពស់បំផុតមួយរបស់រាជរដ្ឋាភិបាល, ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពផ្ទៃដី និងការគ្រប់គ្រងធនធានទឹកដោយយកចិត្តទុកដាក់ផងដែរដល់ការបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ ដែលមានស្រាប់ ការបន្ថុបង្កើត និងពង្រឹងគុណភាពសហគមន៍អ្នកប្រើប្រាស់ទឹក ព្រមទាំងការកាត់បន្ថយភាពងាយរងគ្រោះពីគ្រោះធម្មជាតិ និងការពឹងផ្អែកទាំងស្រុងលើលក្ខណ្ឌធម្មជាតិ ។ល។ និងក្នុងក្របខ័ណ្ឌនេះរាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពជាពិសេសទៅលើការតំរង់ទិសកិច្ចការវិនិយោគសាធារណៈនិងការលើកទឹកចិត្តវិនិយោគឯកជនឱ្យឆ្ពោះទៅរកវិស័យកសិកម្ម សំដៅការលើកកំពស់កំណើនកសិផល និងធានាគុណភាពកសិផលកម្ពុជាឱ្យឆ្លើយតបទៅនឹងការតម្រូវនៃស្តង់ដារអន្តរជាតិ ។

+ចតុកោណទី ២: ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

- ជ្រុងទី ២: ការគ្រប់គ្រងធនធានទឹក និងប្រពន្ធ័ធារាសាស្ត្រ [៣]

+ចតុកោណទី ៣: ការអភិវឌ្ឍផ្នែកឯកជន និងការងារ

- ជ្រុងទី ១: ការពង្រឹងវិស័យឯកជន និងការទាក់ទាញទុនវិនិយោគ [៤]

- ជ្រុងទី ២: ការបង្កើតការងារ និងការធានាលក្ខណ្ឌការងារល្អប្រសើរជូនកម្មករ និងនិយោជិក [៥]

+ចតុកោណទី ៤: ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស

- ជ្រុងទី ៣: ការអនុវត្តន៍គោលនយោបាយសមភាពផ្នែកភេទ (យេនឌ័រ) [៦]

## ១.២-មូលដ្ឋានគ្រឹះទី២ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម

ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម គឺជាភារកិច្ចទទួលខុសត្រូវរបស់ក្រសួងធនធានទឹក និងឧតុនិយម ដែលមានកំណត់នៅក្នុងអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩។ អនុក្រឹត្យនេះ បានកំណត់ពីការទទួលខុសត្រូវរបស់ក្រសួងធនធានទឹក និងឧតុនិយម ដូចមានសង្ខេបជូនខាងក្រោម:

១-កំណត់គោលនយោបាយដែលទាក់ទងនឹងយុទ្ធសាស្ត្រ និងការអភិវឌ្ឍន៍យុទ្ធសាស្ត្រធនធានទឹក

២- សិក្សាស្រាវជ្រាវអំពីធនធានទឹក

៣- រៀបចំផែនការសម្រាប់អភិវឌ្ឍន៍ធនធានទឹក និងធ្វើការអភិរក្ស

៤-គ្រប់គ្រងដោយផ្ទាល់ និងដោយប្រយោលលើការប្រើប្រាស់ទឹក និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីទឹក

៥- រៀបចំច្បាប់ទឹក និងពិនិត្យតាមដានការអនុវត្តន៍

៦- ប្រមូល ចងក្រងទិន្នន័យ និងព័ត៌មានឧតុនិយម និងជលសាស្ត្រ

៧- ផ្តល់ទីប្រឹក្សាបច្ចេកទេស

៨- បន្តកិច្ចគ្រប់គ្រងសហប្រតិបត្តិការអន្តរជាតិរួមទាំងគណ:កម្មការអាងទន្លេមេគង្គ

ចាប់តាំងពីក្រសួងបានបង្កើតឡើងនៅឆ្នាំ១៩៩៩ ការងារអាទិភាពសំខាន់ៗ ៤ របស់ក្រសួងធនធានទឹក និងឧតុនិយម រួមមាន: (១)ការជួសជុល និងស្តារឡើងវិញ (២)ការសាងសង់ (៣)កិច្ចដំណើរការថែទាំនៃប្រពន្ធ័ធារាសាស្ត្រ ការដោះទឹក និង(៤)ហេដ្ឋារចនាសម្ពន្ធ័ត្រួតពិនិត្យទឹកជំនន់។ យុទ្ធសាស្ត្រចតុកោណតម្រូវឱ្យក្រសួងធនធានទឹក និងឧតុនិយមយក

**៣** យុទ្ធសាស្ត្រចតុកោណបានចែងថា រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើ (1)ការផ្តល់ឱ្យពលរដ្ឋគ្រប់រូបនូវទឹកដែលមានសុវត្ថភាព និងប្រកបដោយអនាម័យ (2)ការផ្តល់សេរីភាពដល់ពលរដ្ឋគ្រប់រូបដោយបញ្ចៀសការគំរាមកំហែងបាត់បង់ជីវិត និងលក្ខណ្ឌជីវិតដែលបណ្តាលមកពីភាពចៃដន្យដែលទាក់ទងនឹងទឹក (3)ការផ្តល់ទឹកគ្រប់គ្រាន់ដល់កន្លែងណាដែលត្រូវការ ដើម្បីធានាបាននូវសន្តិសុខស្បៀងសំរាប់ការរស់នៅរបស់ប្រជាជន និងសំរាប់សកម្មភាពសេដ្ឋកិច្ច (4)ការធានាបរិស្ថានទឹកដែលគ្មានជាតិពុល និងការទ្រទ្រង់ជីវិតមច្ឆានិងប្រព័ន្ធអេកូឡូស៊ីនៅក្នុងទឹក ។ រាជរដ្ឋាភិបាលនឹងបន្តអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពផ្ទៃដី និងការគ្រប់គ្រងធនធានទឹកដោយផ្តោតការយកចិត្តទុកដាក់លើការបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ការបន្តបង្កើត និងពង្រឹងគុណភាពសហគមន៍អ្នកប្រើប្រាស់ទឹក និងការកាត់បន្ថយភាពងាយរងគ្រោះពីគ្រោះធម្មជាតិ និងការពឹងផ្អែកទាំងស្រុងលើលក្ខណ្ឌធម្មជាតិ ។

**៤** យុទ្ធសាស្ត្រចតុកោណបានចែងថា រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់លើការទាក់ទាញការចូលរួមរបស់វិស័យឯកជន នៅតាមវិស័យអាទិភាពទាំង៦យ៉ាងដែលបានកំណត់កន្លងមក ដែលវិស័យអាទិភាពមួយគឺ: ការអភិវឌ្ឍន៍វិស័យកសិកម្ម និងកសិឧស្សាហកម្ម ក្នុងនោះផ្តល់អាទិភាពលើការដោះស្រាយទឹកសំរាប់កសិកម្ម ។

**៥** យុទ្ធសាស្ត្រចតុកោណបានចែងថា រាជរដ្ឋាភិបាលបាននឹងកំពុងដាក់ចេញនូវកម្មវិធីដើម្បីបង្កើនផលិតភាពកសិកម្មដែលជាគន្លឹះមួយនាំឱ្យមានកំណើនសេដ្ឋកិច្ច ។ កម្មវិធីនេះមានគោលដៅបង្កើនបរិមាណកសិផល ប្រាក់ចំណូល និងលើកកំកើងកំរិតជីវភាព ព្រមទាំងបង្កើតការងារតាមរយ:ការធ្វើប្រពលវប្បកម្មដាំដុះ នឹងបង្កើនការដាំដុះដំណាំច្រើនមុខ ។ នេះបញ្ជាក់ឱ្យឃើញពីទំនាក់ទំនងនៃការបង្កើនការគ្រប់គ្រងធនធានទឹកសំរាប់វិស័យកសិកម្ម ។

**៦** យុទ្ធសាស្ត្រចតុកោណបានបញ្ជាក់ពីវិស័យជាច្រើនដែលក្នុងនោះក្រសួងធនធានទឹក និងឧតុនិយមអាចរួមចំណែកជាមួយយុទ្ធសាស្ត្រចតុកោណ ជាពិសេសតាមរយ:យន្តការនៃការគ្រប់គ្រងធនធានទឹកនៅថ្នាក់ខេត្ត រួមទាំងការពង្រឹងសមត្ថភាពស្ត្រីលើគ្រប់វិស័យដូចជា ការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចដោយសមធមិមាមឱកាសចូលរួមស្មើគ្នាក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងការចូលរួមយ៉ាងសំខាន់របស់ស្ត្រីនៅគ្រប់កំរិតក្នុងស្ថាប័នរដ្ឋាភិបាល ។

ចិត្តទុកដាក់ទៅលើវិស័យទាំងបួនជាអាទិភាពនៃការទទួលខុសត្រូវរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយក្រសួងធនធានទឹក និងឧតុនិយម ត្រូវតែរិះរកធនធានឱ្យបានគ្រប់គ្រាន់ផ្តល់ឱ្យវិស័យផ្សេងៗ ដើម្បីធានាដល់ការគ្រប់គ្រងធនធានទឹក និងការកាត់បន្ថយគ្រោះធម្មជាតិឱ្យបានខ្លាំងក្លា មានប្រសិទ្ធភាព និងសម្រេចបាននូវគោលបំណងប្រកបដោយចិរភាព ។

## ១.៣_មូលដ្ឋានគ្រឹះទី៣ គោលនយោបាយជាតិលើវិស័យធនធានទឹកនៅកម្ពុជា

ដើម្បីចូលរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ក្រសួងធនធានទឹក និងឧតុនិយម បានកំណត់យកឯកសារស្តីពី **"គោលនយោបាយជាតិលើវិស័យធនធានទឹក"** ធ្វើជាមូលដ្ឋានគ្រឹះក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយមប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាព ។ គោលនយោបាយជាតិលើវិស័យធនធានទឹកនៅកម្ពុជាមាន**ចក្ខុវិស័យទឹក**ដូចខាងក្រោម ÷

- ផ្តល់លទ្ធភាពឱ្យដល់ជនគ្រប់រូប ក្នុងការប្រើប្រាស់ទឹកសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រប់គ្រាន់ប្រកបដោយអនាម័យល្អ មានសុវត្ថិភាព និងតម្លៃសមស្រប
- ផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ដល់វិស័យកសិកម្ម ឧស្សាហកម្ម និងសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត
- ដោះស្រាយ និងកាត់បន្ថយឱ្យបានជាអតិបរមា នូវគ្រោះគំរាមកំហែងដល់អាយុជីវិត និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ពីមហន្តរាយដែលបង្កឡើងដោយទឹក
- គ្រប់គ្រងបរិស្ថានធនធានទឹកដែលគ្មានសារធាតុបំពុល ។

ទន្ទឹមនឹងនេះ យើងក៏មានយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក (២០០៦-២០១០)ដែលបានរៀបចំឡើងដោយក្រសួងធនធានទឹក និងឧតុនិយម រួមជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍ ។ យុទ្ធស្ត្រនេះក៏មានគោលបំណងឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយមានទស្សនៈវិស័យសម្រាប់រយៈពេលវែង គឺធានាឱ្យមាន ទឹកគ្រប់គ្រាន់ និងមានសុវត្ថភាពសម្រាប់ប្រជាជនគ្រប់រូប ធានាឱ្យមានស្បៀងគ្រប់គ្រាន់ កាត់បន្ថយភាពក្រីក្រ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច ពិសេសធានាបាននូវនិរន្តរភាពធនធានធម្មជាតិផងដែរ ។

## ២_ស្ថានភាពវិស័យទឹក_ ការវិភាគអំពីស្ថានភាព

### ២.១_ទឹក និងតម្រូវការ

ដោយសារតែមានទន្លេមេគង្គ និងល្អាងទឹកធម្មជាតិក្រោមដីធំៗប្រទេសកម្ពុជាត្រូវបានចាត់ទុកថាជាប្រទេសសំបូរដោយទឹក ហើយបានគណនាថាមានបរិមាណលំហូរទឹកចំនួន ៤៧៥ ពាន់លានម៉ែត្រគូប ដែលបានមកពីប្រព័ន្ធទន្លេមេគង្គ និងទន្លេសាប និងបរិមាណទឹកក្រោមដីចំនួន ១៧.៦០០ លានម៉ែត្រគូប ។ ទន្លេមេគង្គ និងបឹងទន្លេសាប គឺជាប្រភពធនធានដ៏មានតម្លៃសម្រាប់ ការស្រោចស្រព វារីអគ្គីសនី ផលិតផលត្រី កសិកម្ម ជីវសាស្ត្រចំរុះ ការដឹកជញ្ជូន និងការធ្វើដំណើរតាមផ្លូវទឹក ។

រដូវប្រាំងដែលមានរយៈពេលយូរ បានធ្វើឱ្យទឹកហួតហែង និងកម្ពស់ទឹកទន្លេបានស្រកចុះ ។ នៅតាមកន្លែងខ្លះការផ្គត់ផ្គង់ទឹកគឺមានរយៈពេលខ្លី និងមានការដណ្តើមទឹកប្រើប្រាស់ ហើយគុណភាពទឹកបានទទួលរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ ។ ទាំងនេះបង្កើតឱ្យមានការដណ្តើមទឹកដែលមានគុណភាពល្អសម្រាប់ប្រើប្រាស់ដូចជា ផឹក ចិញ្ចឹមសត្វ ការថែទាំ

ប្រព័ន្ធបរិស្ថានក្នុងទឹក។ល។ ដោយមានការអភិវឌ្ឍលើវិស័យកសិកម្ម ការធ្វើប្រពលវប្បកម្ម និងកំណើនប្រជាជននៅក្នុងក្រុង នឹងមានការគម្រាមគំហែងកើនឡើងទៅលើគុណភាពទឹក។

នៅរដូវវស្សា ទឹកច្រើនអាចបណ្តាលឱ្យជន់លិច បាត់បង់អាយុជីវិត ខូចខាតផលិតផលកសិកម្ម ទ្រព្យសម្បត្តិ និងហេដ្ឋារចនាសម្ព័ន្ធ។ ការកាត់បន្ថយគ្រោះទឹកជំនន់សំខាន់រួមមាន ការព្យាករណ៍ទឹកជំនន់នៅតាមដងទន្លេមេគង្គ និងទំនប់ការពារទប់ស្កាត់ទឹកជំនន់កុំឱ្យលិចទីក្រុង និងរាជធានីភ្នំពេញ។

ប្រទេសកម្ពុជាពឹងផ្អែកលើកសិកម្ម ៨០%នៃប្រជាជនប្រមាណ ១២លាននាក់រស់នៅតាមជនបទ។ ផ្ទៃដីដាំដុះប្រហែល ៨០% និងកសិករបានប្រឈមមុខទៅនឹងការធ្លាក់ចុះនៃការដាំដុះ ឬទិន្នផលបានធ្លាក់ចុះដែលបណ្តាលមកពីគ្រោះរាំងស្ងួត ឬកំដៅហួតហែង។ ភាគតិចនៃផ្ទៃដីដាំដុះ មានប្រពន្ធ័ស្រោចស្រព ដែលផ្តត់ផ្គង់ដល់ការដាំដុះចម្រុះ ហើយការស្រោចស្រពភាគច្រើន គឺជាការស្រោចស្រពបន្ថែម។ ជាលទ្ធផលការដណ្តើមទឹកប្រើប្រាស់ដោយគ្មានការត្រួតពិនិត្យបង្ហាញឱ្យឃើញពីការគំរាមគំហែងយ៉ាងធ្ងន់ធ្ងរទៅលើធនធានទឹក ។

## ២.២ ក្របខ័ណ្ឌស្ថាប័ន

ការរៀបចំស្ថាប័ននៅក្នុងវិស័យទឹកមានការផ្លាស់ប្តូរយ៉ាងលឿន។ ក្រសួងធនធានទឹក និងឧតុនិយម បានបង្កើតឡើងនៅឆ្នាំ ១៩៩៩ ដែលជាភ្នាក់ងារដឹកនាំវិស័យធនធានទឹក សព្វថ្ងៃនេះច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានព្រះករុណាឡាយព្រះហស្តលេខាប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ រីឯគោលនយោបាយជាតិលើវិស័យធនធានទឹកបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៤។ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រាងទន្លេមេគង្គនៅឆ្នាំ ១៩៩៧ ហើយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាជាអ្នកផ្តល់យោបល់ទៅរាជរដ្ឋាភិបាលស្តីពីទស្សនៈនៃការគ្រប់គ្រងធនធានទឹកនៅតាមដងទន្លេមេគង្គ ។

ក្រៅពីក្រសួងធនធានទឹក និងឧតុនិយម ក្រសួងពាក់ព័ន្ធមួយចំនួនមានភារៈកិច្ចទទួលខុសត្រូវពាក់ព័ន្ធលើបញ្ហាទឹក ឧទាហរណ៍ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (ការប្រើប្រាស់ទឹកសម្រាប់វារីអគ្គីសនី ឧស្សាហកម្ម ការផ្គត់ផ្គង់ទឹកនៅតាមក្រុង) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(កសិកម្ម ការនេសាទ និងព្រៃឈើ ដែលបានប្រើប្រាស់ទឹកយ៉ាងច្រើននៅកម្ពុជា) និងក្រសួងបរិស្ថាន (ការការពារធនធានធម្មជាតិ និងគុណភាពបរិស្ថាន រួមទាំងទឹកផងដែរ)។ **ក្រសួងធនធានទឹក និងឧតុនិយម មានការទទួលខុសត្រូវរួម (ជាទូទៅ)** ដើម្បីធានាថាធនធានទឹកត្រូវបានគ្រប់គ្រងប្រើប្រាស់ឱ្យមាននិរន្តរភាពសម្រាប់វិស័យផ្សេងៗទៀត ។

ផ្នែកសំខាន់ៗនៃការគ្រប់គ្រងធនធានទឹក គឺជាសមត្ថភាពរបស់ស្ថាប័នដែលពាក់ព័ន្ធនឹងវិស័យទឹកនៅថ្នាក់ជាតិ ហើយរាជរដ្ឋាភិបាលក៏បានផ្តល់ការទទួលខុសត្រូវខ្លះចំពោះថ្នាក់ក្រោមជាតិ។ ក្រសួងធនធានទឹក និងឧតុនិយម បានផ្តល់សិទ្ធិដល់មន្ទីរធនធានទឹក និងឧតុនិយមខេត្ត-រាជធានី ក្នុងការអនុវត្តន៍គម្រោង និងសកម្មភាពផ្សេងៗទៀត។ ក្រសួងក៏កំពុងតែបានបង្កើតសមត្ថភាពអ្នកប្រើប្រាស់ទឹក ដើម្បីភ្ជាប់ទៅនឹងការប្រើប្រាស់ធនធានទឹក ជាពិសេសតាមរយៈការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក គឺដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រចតុកោណនៃការធ្វើវិមជ្ឈការ វិសហមជ្ឈការ និងការគ្រប់គ្រងធនធានទឹកឱ្យមាននិរន្តរភាព នឹងតម្រូវឱ្យមានថវិកាគ្រប់គ្រាន់ ព័តិមាន និងទិន្នន័យជាមូលដ្ឋាន ព្រមទាំងការពង្រឹងសមត្ថភាពឱ្យបានទូលំទូលាយនៅថ្នាក់ក្រោមជាតិ ។

## ២.៣. បញ្ហាតាមផ្នែក

បញ្ហា និងឧបសគ្គមួយចំនួន ដែលបានរាំងដល់ក្រសួងធនធានទឹក និងឧតុនិយមមិនអាចសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក៏ដូចផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មមានៈ

**ច្បាប់ និងគោលនយោបាយ:** ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកត្រូវបានអនុម័តឱ្យប្រើប្រាស់ជាផ្លូវការរួចហើយ ប៉ុន្តែអនុក្រឹត្យមួយចំនួនពុំទាន់មាន ហើយត្រូវតែបង្កើត ដើម្បីផ្តល់អំណាច និងយន្តការចាំបាច់សម្រាប់ការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធភាព ជាពិសេសគឺ អាជ្ញាប័ណ្ណទឹក សហគមន៍កសិករប្រើប្រាស់ទឹក ការការពារគុណភាពទឹក និងការគ្រប់គ្រងអាងទន្លេ ។

**ការរៀបចំស្ថាប័ន:** យន្តការសម្រាប់ការសម្របសម្រួលអន្តរក្រសួងចាំបាច់ត្រូវតែធ្វើការពង្រឹង។ ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹកផ្តល់ឱ្យនូវមូលដ្ឋានមួយ។ ទោះជាយ៉ាងណាក៏ដោយ តម្រូវការចាំបាច់នៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើការពង្រឹងបទដ្ឋានបច្ចេកទេសការងារសម្រាប់ការផ្ទេរ ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹកទៅឱ្យសហគមន៍កសិករប្រើប្រាស់ទឹកជាអ្នកគ្រប់គ្រង។

**សមត្ថភាពស្ថាប័ន:** សមត្ថភាពបច្ចេកទេសនៅក្រសួង និងមន្ទីរធនធានទឹក និងឧតុនិយមខេត្ត-រាជធានី និងនៅមូលដ្ឋាន (រួមទាំងសហគមន៍កសិករប្រើប្រាស់ទឹក) តម្រូវឱ្យមានការអភិវឌ្ឍ ជាពិសេសជំរុញឱ្យមានការទទួលខុសត្រូវលើការគ្រប់គ្រងធនធានទឹកដែលនឹងត្រូវធ្វើវិមជ្ឈការ ។

**ទិន្នន័យ និងព័ត៌មាន:** មូលដ្ឋានទិន្នន័យ និងព័ត៌មានចាំបាច់ ដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធទាក់ទងនឹងទឹក ការគ្រប់គ្រងធនធានទឹក និងធ្វើការកែលំអ ការកាត់បន្ថយផលប៉ះពាល់ដោយទឹកជំនន់ និងគ្រោះរាំងស្ងួត។ ការកាត់បន្ថយផលប៉ះពាល់ ជាពិសេសក្នុងករណីអាងទន្លេ ដែលមានការប្រកួតប្រជែង ឬដណ្តើមទឹកប្រើប្រាស់។

**ការកាត់បន្ថយផលប៉ះពាល់នៃគ្រោះថ្នាក់បណ្តាលមកពីទឹក:** វិធីសាស្ត្រចាំបាច់សម្រាប់កាត់បន្ថយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត រួមទាំងការធ្វើអន្តរាគមន៍នានា មានការងារសាងសង់ទំនប់ អន្តរាគមន៍បូមទឹកសង្គ្រោះដំណាំស្រូវ និងការងារផ្សេងៗ បញ្ចូលទៅក្នុងកម្មវិធីដែលមានខ្ទង់ចំណាយ និងមានប្រសិទ្ធភាព។

**ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធដោះទឹក និងហេដ្ឋារចនាសម្ព័ន្ធ:** លើកកម្ពស់ការត្រួតពិនិត្យទឹក (ផ្នែកខាងលើ និងខាងក្រោមអាង ឬប្រព័ន្ធ) និងទិន្នន័យទឹកភ្លៀង សំខាន់គឺនៅតំបន់ជនបទ ដើម្បីកាត់បន្ថយការពឹងផ្អែករបស់កសិករដែលពឹងទៅលើទឹកភ្លៀង និងជួយជំរុញផលិតផលកសិកម្មឱ្យកើនឡើង ប៉ុន្តែមានការលំបាក និងប្រឈមខ្លះៗរួមមានៈ

**ក)** ជ្រើសរើសប្រព័ន្ធស្រោចស្រព និងដោះទឹកសម្រាប់ជួសជុល ដែលនឹងផ្តល់នូវចំណូលសេដ្ឋកិច្ច និងសង្គមយ៉ាងខ្ពស់ចំពោះការធ្វើអន្តរាគមន៍ ។

**ខ)** ធ្វើសមាហរណកម្មឃុំឱ្យមានប្រសិទ្ធភាព និងមាននិរន្តភាពដើម្បីគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រឃុំ

**គ)** លើកទឹកចិត្តដល់កសិករនិមួយៗឬក្រុមតូចៗដើម្បីឱ្យពួកគាត់ផ្តល់សេវាគ្រប់គ្រងទឹក ជាពិសេសលើទីតាំងប្រព័ន្ធស្រោចស្រពក្នុងឃុំដែលមិនអាចអនុវត្តទៅបាន ។

**ឃ)** គ្រប់គ្រងទឹកឱ្យមាននិរន្តរភាព សមធម៌ និងប្រើប្រាស់ទឹកតាមអាងទន្លេ ឱ្យមានប្រសិទ្ធភាពដែលតម្រូវការ

ប្រើប្រាស់លើសពីការផ្តល់ឱ្យ ។

៦) ដាក់វិធានការលើកកម្ពស់ការគ្រប់គ្រងធនធានទឹក ឱ្យស៊ីគ្នាទៅនឹងវិធានការដែលមានគោលបំណងបង្កើនផលិតផលកសិកម្មតាមមធ្យោបាយផ្សេងៗ ។

## ៣.បេសកកម្ម យុទ្ធសាស្ត្រការងារសំខាន់ៗ និងគោលដៅរបស់ក្រសួងធនធានទឹក និងឧតុនិយម

### ៣.១.បេសកកម្ម និងគោលបំណង

#### ៣.១.១.បេសកកម្ម :

ដើម្បីអនុវត្តនូវផែនការយុទ្ធសាស្ត្រ និងសកម្មភាព ២០០៩-២០១៣ ទទួលបានជោគជ័យ នឹងឈានទៅសម្រេចបាននូវចក្ខុវិស័យជាតិលើវិស័យធនធានទឹក ក្រសួងធនធានទឹក និងឧតុនិយម បានកំណត់គោលដៅសម្រាប់បេសកកម្មដូចតទៅ: **"ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់ សមធម៌ និងនិរន្តរភាព ដើម្បីធានាបាននូវប្រព័ន្ធអេកូឡូស៊ី និងកាត់បន្ថយនូវគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិដូចជា ទឹកជំនន់ ភាពរាំងស្ងួតមកលើការរស់នៅ និងទ្រព្យសម្បត្តិសាធារណៈ "** ។

#### ៣.១.២.គោលបំណង:

ដើម្បីសម្រេចបាននូវបេសកកម្មរបស់ក្រសួង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី២ ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ក្រសួងធនធានទឹក និងឧតុនិយមមានគោលបំណងដូចខាងក្រោម :

-បង្កើនលទ្ធភាពស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រឱ្យបាន ១% ក្នុង ១ឆ្នាំ គិតជាផ្ទៃដីស្រូវ ២៥.០០០ហ.ត បន្ថែមលើសក្តានុពលលទ្ធភាពស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រទាំងអស់មាន ១.១២០.២៤៦ហ.ត **ដោយធ្វើអនុត្តរភាពប្រព័ន្ធធាសាស្ត្រដែលមានស្រាប់ និងសាងសង់ប្រព័ន្ធធារាសាស្ត្រថ្មី** បន្ថែមនៅតំបន់ដែលពិនិត្យឃើញថាមានសក្តានុពលទឹកដើម្បីឈានទៅធ្វើស្រែពីរដងក្នុងមួយឆ្នាំ សម្រាប់បង្កើនចំណូលក៏ដូចជាបង្កើនការងារជូនប្រជាកសិករនៅតាមជនបទ ។ ដូច្នេះ យើងមានសូចនាករដូចខាងក្រោម:

| សូចនាករ (ហ.ត) | ឆ្នាំ២០០៨ (ហ.ត) | ឆ្នាំ២០០៩ ការប៉ាន់ស្មាន (ហ.ត) | ឆ្នាំ២០១០ ព្យាករណ៍ (ហ.ត) | ឆ្នាំ២០១១ ព្យាករណ៍ (ហ.ត) | ឆ្នាំ២០១២ ព្យាករណ៍ (ហ.ត) | ឆ្នាំ២០១៣ ព្យាករណ៍ (ហ.ត) |
|---|---|---|---|---|---|---|
| ២៥.០០០ | ១.១២០.២៤៦ | ១.១៤៥.២៤៦ | ១.១៧០.២៤៦ | ១.១៩៥.២៤៦ | ១.២២០.២៤៦ | ១.២៤៥.២៤៦ |

-អនុវត្តគោលនយោបាយជាតិលើវិស័យធនធានទឹកនៅកម្ពុជា តាមរយៈការថែទាំ ការស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ ទំនប់ការពារទប់ស្កាត់ទឹកជំនន់-ទឹកប្រៃ ប្រព័ន្ធដោះទឹក និងទំនប់វារីអគ្គិសនី ។

-ផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមានការចូលរួមពីកសិករជាពិសេស កសិករជាស្ត្រី និងអភិវឌ្ឍន៍ឱ្យមាននិរន្តរភាពក្នុងវិស័យធនធានទឹក ។

-រៀបចំសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីកាត់បន្ថយនូវការចំណាយរបស់រដ្ឋលើការងារថែទាំ និងធានាឱ្យបាននូវនិរន្តរភាពរបស់ប្រព័ន្ធធារាសាស្ត្រ ដោយលើកទឹកចិត្តស្ត្រីចូលរួមឱ្យបានច្រើន ។

-កសាងស្ថានីយបូមទឹកបន្ថែមទៀត

-អនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យធនធានទឹក និងឧតុនិយម

-គ្រប់គ្រងច្រាំងទន្លេ-ស្ទឹង-ព្រែក លើការហូរច្រោះដី កកដី និងការបាក់ច្រាំង

-ក្តាប់នូវទិន្នន័យជលសាស្ត្រឱ្យបានល្អប្រសើរ ដើម្បីបម្រើឱ្យការស្រាវជ្រាវ និងវាយតម្លៃនូវសក្តានុពលទឹកលើដី និងក្រោមដី ព្រមទាំងពិនិត្យការបំរែបំរួលទឹក និងតំបន់ដីសើម ដែលមានសារៈសំខាន់ដល់វិស័យកសិកម្ម ។

-ក្តាប់ឱ្យបាននូវការប្រែប្រួលនៃធាតុអាកាស ដូចជាល្បាក់ខ្យល់ក្នុងបរិយាកាស សិក្សាឌីណាមិក ស៊ីណុបទិច ។ល ។

-ព្យាករណ៍ធាតុអាកាសឱ្យបានទៀងទាត់ និងផ្សព្វផ្សាយឱ្យបានមុនពេលគ្រោះមហន្តរាយពីធម្មជាតិកើតឡើង ។

-អនុវត្តយុទ្ធសាស្ត្រសម្រាប់កសិកម្ម និងទឹក

## ៣.២-យុទ្ធសាស្ត្រសំខាន់ៗរបស់ក្រសួងធនធានទឹក និងឧតុនិយម

ដើម្បីសម្រេចបេសកកម្ម និងគោលបំណងរបស់ក្រសួង ក៏ដូចជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី២ ឆ្នាំ២០០៩-២០១៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ ឱ្យបានខ្លាំងក្លា ក្រសួងធនធានទឹក និងឧតុនិយមបានរៀបចំយុទ្ធសាស្ត្រ ដើម្បីគាំទ្រដល់មុំទាំងបួននៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងគោលបំណងធ្វើឱ្យសម្រេចបាននូវគោលនយោបាយជាតិ ស្តីពីការកាត់បន្ថយភាពក្រីក្រ ។ យុទ្ធសាស្ត្រសំខាន់ៗរបស់ក្រសួងធនធានទឹក និងឧតុនិយម មាន :

(១) ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក

(២) ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត

(៣) ការជំរុញរៀបចំសេចក្តីព្រាងច្បាប់-បញ្ញត្តិ សម្រាប់និរន្តរភាពនៃទឹក

(៤) ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹក និងឧតុនិយម

(៥) ការកែលំអការគ្រប់គ្រង រដ្ឋបាល និងអភិវឌ្ឍន៍ធនធានមនុស្ស ។

យុទ្ធសាស្ត្រចំនួន ២ដែលក្រសួងធនធានទឹក និងឧតុនិយម បានបង្កើតជាគោលដៅអាទិភាពមាន:

-ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក

-ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត

យុទ្ធសាស្ត្រទាំងពីរនេះរួមចំណែកផ្ទាល់ក្នុងការសម្រេចបានគោលដៅអាទិភាពជាតិ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណ ។

យុទ្ធសាស្ត្រចំនួន ៣ដែលក្រសួងធនធានទឹក និងឧតុនិយមបានបង្កើតជាគោលដៅអភិវឌ្ឍន៍ស្ថាប័នមាន:

-ការជំរុញរៀបចំសេចក្តីព្រាងច្បាប់-បញ្ញត្តិ សម្រាប់និរន្តរភាពនៃទឹក

-ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹក និងឧតុនិយម

-ការកែលំអការគ្រប់គ្រង រដ្ឋបាល និងអភិវឌ្ឍន៍ធនធានមនុស្ស ។

យុទ្ធសាស្ត្រទាំង ៣នេះរួមចំណែកឱ្យយុទ្ធសាស្ត្រចតុកោណដោយប្រយោល ដោយជួយជំរុញឱ្យក្រសួងធនធានទឹក និងឧតុនិយម អនុវត្តការងារបានប្រសើរជាងមុន ។ ទោះជាយ៉ាងណាក៏ដោយ ក៏គោលដៅមួយចំនួនរួមចំណែកផ្ទាល់ជាមួយ

គោលដៅយុទ្ធសាស្ត្រចតុកោណ ជាពិសេសតាមរយៈការផ្ទេរអំណាចនៃការទទួលខុសត្រូវទៅសហគមន៍កសិករប្រើប្រាស់ទឹក និងស្ត្រី ។

សរុបមកយុទ្ធសាស្ត្រទាំង ៥ នេះរួមចំណែកឱ្យសម្រេចបាននូវគោលដៅសំខាន់ៗ នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ។

## ៣.៣ លក្ខណៈវិនិច្ឆ័យជាអាទិភាព

លក្ខណៈវិនិច្ឆ័យដែលបានប្រើសម្រាប់ជ្រើសរើសគោលដៅកម្មវិធី និងសកម្មភាព ស្របតាមយុទ្ធសាស្ត្ររបស់ក្រសួង និងគោលដៅយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ផ្តល់នូវក្របខ័ណ្ឌសម្រាប់ជ្រើសរើសលក្ខណៈវិនិច្ឆ័យ ។ ជាមួយក្របខណ្ឌនេះ លក្ខណៈវិនិច្ឆ័យជាច្រើនប្រើដើម្បីកំណត់គោលដៅរបស់ក្រសួងធនធានទឹក និងឧតុនិយម រួមមានៈ

-សមត្ថភាពរបស់ក្រសួងធនធានទឹក និងឧតុនិយម

-រួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យមាននិរន្តរភាព រីកចំរើន មានសមធម៌ និងកាត់បន្ថយភាពក្រីក្រ

-ជំរុញការអភិវឌ្ឍន៍សង្គម

-ការគ្រប់គ្រង និងប្រើប្រាស់ធនធានទឹកឱ្យមាននិរន្តរភាពជាមួយធម្មជាតិ និងបរិស្ថាន

-អភិបាលកិច្ច តាមរយៈការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពនៃផែនការសកម្មភាពអភិបាលកិច្ចល្អ

ដូច្នេះគោលដៅ និងសកម្មភាពរបស់ក្រសួងធនធានទឹក និងឧតុនិយមឆ្នាំ២០០៩-២០១៣មានពីរប្រភេទសំខាន់ៗ សម្រាប់ចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម :

**គោលដៅអាទិភាពជាតិ** : ការជួសជុល និងស្តារឡើងវិញ ការប្រើប្រាស់ និងការថែទាំប្រពន្ធ័ធារាសាស្ត្រ ប្រព័ន្ធដោះទឹក និងហេដ្ឋារចនាសម្ពន្ធ័គ្រប់គ្រងទឹកជំនន់ ។

**គោលដៅអភិវឌ្ឍន៍ស្ថាប័ន** : កិច្ចដំណើរការ និងការកែលំអនៃការគាំទ្រសេវាកម្មនានាដូចជា ផ្នែករដ្ឋបាល ការគ្រប់គ្រងព័ត៌មាន ទិន្នន័យ ឬការបណ្តុះបណ្តាល ។

ប្រភេទទាំងពីរនេះ គឺជាលក្ខណៈវិនិច្ឆ័យសំខាន់ៗ ប្រើដើម្បីដាក់សំណើសុំថវិកាជាតិ ឬភ្នាក់ងារផ្តល់ជំនួយបរទេស ( ម្ចាស់ជំនួយ) ។

## ៣.៤ គោលដៅសំខាន់ៗរបស់ក្រសួងធនធានទឹក និងឧតុនិយម

ដើម្បីអនុវត្តយុទ្ធសាស្ត្រសំខាន់ៗទាំង៥ខាងលើ ក្រសួងធនធានទឹក និងឧតុនិយម បានបង្កើតគោលដៅចំនួន៩ ក្នុងគោលដៅទាំងពីរប្រភេទនៃលក្ខណៈវិនិច្ឆ័យខាងលើ ដើម្បីរួមចំណែកឱ្យសម្រេចបានបេសកម្ម និងគោលបំណងរបស់ក្រសួង ។ គោលដៅសំខាន់ៗ ទាំង៥ មានបង្ហាញនៅក្នុងតារាងខាងក្រោម :

| **យុទ្ធសាស្ត្រការងារ** | **គោលដៅសំខាន់ៗសម្រាប់ឆ្នាំ ២០០៩-២០១៣** |
|---|---|
| (១) ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក | ១.១ ធនធានទឹករបស់ប្រទេសកម្ពុជាត្រូវបានគ្រប់គ្រង និងអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធភាព សមធម៌ និងមាននិរន្តរភាព ។ ទាំងនេះធ្វើឱ្យសម្រេចបាននូវអត្ថប្រយោជន៍ ជាច្រើនសម្រាប់ប្រជាជន ។<br>១.២ អនុវត្តគោលនយោបាយអនុត្តរភាពប្រព័ន្ធធារាសាស្ត្រ |

| | |
|---|---|
| (២) ការគ្រប់គ្រងទឹកជំនន់ និង គ្រោះរាំងស្ងួត | ២.ផលប៉ះពាល់នៃគ្រោះថ្នាក់ដែលបណ្តាលមកពីទឹក ជាពិសេស គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត មកលើជីវិតរស់នៅ ទ្រព្យសម្បត្តិ ការរស់នៅចិញ្ចឹមជីវិតរបស់ប្រជាជនកម្ពុជា និងទ្រព្យសម្បត្តិសាធារណៈ ត្រូវបានកាត់បន្ថយ ។ |
| (៣) ការជំរុញរៀបចំសេចក្តីព្រាងច្បាប់-បញ្ញត្តិសម្រាប់និរន្តរភាពនៃទឹក | ៣.ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកបានបង្កើតឡើង សម្រាប់ធ្វើការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកឱ្យមានប្រសិទ្ធភាព និងមានសមធម៌ ។ |
| (៤) ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹក និងឧតុនិយម | ៤.ធនធានទឹករបស់កម្ពុជាត្រូវបានអភិវឌ្ឍន៍ និងគ្រប់គ្រងយ៉ាងយកចិត្តទុកដាក់ប្រកបដោយគតិបណ្ឌិត ដោយឈរលើព័ត៌មាន និងទិន្នន័យគ្រប់គ្រាន់ ។ |
| (៥) ការកែលំអការគ្រប់គ្រងរដ្ឋបាល និងអភិវឌ្ឍន៍ធនធានមនុស្ស ។ | ៥.ពង្រឹង និងកែលំអរប្រព័ន្ធរដ្ឋបាល និងប្រព័ន្ធគ្រប់គ្រង សមត្ថភាពបច្ចេកទេស សេវា និងធនធានមនុស្សនៃក្រសួងធនធានទឹក និងឧតុនិយម និងថ្នាក់ក្រោមជាតិ ដើម្បីជំរុញឱ្យការអនុវត្តការងារ និងការគ្រប់គ្រងបានល្អប្រសើរ និងមានប្រសិទ្ធភាព ។ |

### ៣.៥_គោលដៅក្នុងការបង្កើនសមត្ថភាពយេនឌ័រនៅក្នុងវិស័យធនធានទឹក

បន្ថែមលើយុទ្ធសាស្ត្រ និងគោលដៅទាំងប្រាំខាងលើ ក្រសួងធនធានទឹក និងឧតុនិយម បន្តចូលរួមអនុវត្តគោលនយោបាយសមភាពយេនឌ័ររបស់រាជរដ្ឋាភិបាលដោយមានគោលដៅដូចខាងក្រោម :

-ចូលរួមចំណែកក្នុងការកសាងសមត្ថភាពស្ត្រី និងការអភិវឌ្ឍធនធានមនុស្ស និងក្នុងការកាត់បន្ថយភាពក្រីក្រ និងបង្កើនសមភាពយេនឌ័រ ។

-បង្កើនឱកាស និងលើកកម្ពស់ស្ត្រីក្នុងការរួមចំណែកនៅក្នុងផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយ

-បន្តស្វែងរកការគាំទ្រមតិតាមរយៈការបង្កើនការយល់ដឹង និងការវិភាគយេនឌ័រដល់បណ្តាការងារយេនឌ័រ គ្រប់លំដាប់ថ្នាក់តាមនាយកដ្ឋាន និងគ្រប់ខេត្ត-រាជធានី ។

-បង្កើនសមត្ថភាពមន្ត្រីជាស្ត្រីតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលនានា និងបន្តការសិក្សាក្នុង និងក្រៅប្រទេស

-ផ្តល់ឱកាស និងជំរុញលើកទឹកចិត្តដល់មន្ត្រីជាស្ត្រីនៃក្រសួងធនធានទឹក និងឧតុនិយម

-ធានាថា រាល់សេវាកម្មនានាដែលទាក់ទងនឹងវិស័យធនធានទឹក បានបម្រើផលប្រយោជន៍កាន់តែច្រើនដល់ស្ត្រីនៅតាមសហគមន៍កសិករប្រើប្រាស់ទឹក ។

## ៤_ផែនការសកម្មភាពក្នុងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយម

ដើម្បីសម្រេចបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម ឱ្យបានជោគជ័យ តាមលក្ខណៈវិនិច្ឆ័យខាងលើ ក្រសួងធនធានទឹក និងឧតុនិយម បានរៀបចំលំដាប់អាទិភាពនៃវិស័យសំខាន់៧សម្រាប់រៀបចំផែនការសកម្មភាពក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយមរយៈពេល ៥ឆ្នាំ ២០០៩-២០១៣ ដូចខាងក្រោម:

## ៤.១_ការគ្រប់គ្រង និងអភិវឌ្ឍធនធានទឹក

**ទឹក** ដើរតួនាទីយ៉ាងសំខាន់ ក្នុងការសម្រេចឱ្យបាននូវគោលដៅចំបងរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ បង្កើនសមត្ថភាពយេនឌ័រ ការអភិវឌ្ឍសេដ្ឋកិច្ច សន្តិសុខស្បៀង និងការអភិរក្សបរិស្ថាន។ **ទឹក** គឺជាធនធាន មូលដ្ឋាន ទ្រទ្រង់ដល់វិស័យនានាដូចជា កសិកម្ម ឧស្សាហកម្ម ថាមពល ការប្រើប្រាស់ក្នុងគ្រួសារ នាវាចរណ៍ ទេសចរណ៍ ជលផល និងការថែរក្សាប្រព័ន្ធអេកូឡូស៊ី។ ដូចនេះការបែងចែកទឹក ត្រូវតែធ្វើឱ្យមានតុល្យភាពចំពោះតម្រូវការក្នុងវិស័យ ខាងលើ ដើម្បីប្រើប្រាស់ទឹកឱ្យអស់ពីលទ្ធភាពសម្រាប់ផលប្រយោជន៍ជាតិ។

ជារៀងរាល់ឆ្នាំ ប្រជាកសិករតែងប្រឈមនឹងការខ្វះខាតទឹក គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់។ បញ្ហាទាំងនេះបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ផលិតផលកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធសង្គម។ ពេលបច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅមានកម្រិតនៅឡើយ ហើយលទ្ធភាពផ្តល់ទឹកពុំទាន់គ្រប់គ្រាន់សម្រាប់ផលិតផលកសិកម្ម។

ការចូលរួមពីអ្នកទទួលផល ជាពិសេសស្ត្រី និងថ្នាក់ក្រោមជាតិ ក្នុងការរៀបចំផែនការជួសជុល គ្រប់គ្រង និងប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធត្រួតពិនិត្យទឹកជំនន់ និងការពារទឹកប្រៃមានសារៈសំខាន់ណាស់។

អាងទន្លេ និងល្អាងទឹកធម្មជាតិក្រោមដី គឺជាមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំផែនការ ការអភិវឌ្ឍ ការគ្រប់គ្រង និងការបែងចែកធនធានទឹកប្រកបដោយសមធម៌ និងមាននិរន្តរភាព ព្រមទាំងមូលដ្ឋានជីវៈរូបនៃវដ្តទឹក។ នៅក្នុងប្រទេសកម្ពុជា បឹងបួរ និងតំបន់ដីសើម ក៏មានតួនាទីយ៉ាងសំខាន់នៅក្នុងវដ្តទឹកផងដែរ ព្រមទាំងធនធានដែលមាននៅក្នុងទឹក និងជលផលដែលប្រជាជនកម្ពុជាបានពឹងផ្អែកទាំងស្រុងសម្រាប់ការផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ។

កន្លងមក ការគ្រប់គ្រង និងការអភិវឌ្ឍលើអាងទន្លេនៅមានកម្រិតនៅឡើយ ដោយខ្វះខាតនូវប្រភពធនធានមនុស្ស ថវិកា ច្បាប់ បច្ចេកវិទ្យា។ល។ ដែលជាហេតុធ្វើឱ្យមានការចាប់យកដីធ្លី ការសាងសង់ ការកាប់ព្រៃឈើ និងការធ្វើអាជីវកម្មខុសច្បាប់ ។ បញ្ហាទាំងអស់ខាងលើនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើអាងទន្លេ ដូចជា ការហូរច្រោះដី ការរងកករដីនៅបាតទន្លេ-ស្ទឹង ការប្រែប្រួលគុណភាពទឹក ការប្រែប្រួលទ្រង់ទ្រាយទន្លេ ការផ្លាស់ប្តូររបបទឹក ទឹកជំនន់ និងភាពរាំងស្ងួត ព្រមទាំងប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិយ៉ាងខ្លាំងផងដែរ។

នៅជុំវិញបឹងទន្លេសាប តាមដងទន្លេមេគង្គ និងតំបន់ដទៃទៀត នៅទូទាំងប្រទេសកម្ពុជា ពុំអាចទទួលបានទិន្នផលខ្ពស់ពីការបង្កបង្កើនផលកសិកម្មរបស់ខ្លួន ដោយសារការពុំមានការចូលរួមពីកសិករ ដោយយល់ថាប្រព័ន្ធធារាសាស្ត្រជារបស់រដ្ឋ ហើយពឹងផ្អែកតែទៅលើតួនាទីរបស់រាជរដ្ឋាភិបាល។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងធានាការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ដល់កសិកម្ម ក្រសួងធនធានទឹក និងឧតុនិយម **មានផែនការសកម្មភាព** ដូចតទៅ ៖

(១) ស្តារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ក្នុងគោលបំណងឆ្លើយតបជាបន្ទាន់នូវតម្រូវការទឹកសម្រាប់កសិកម្ម។

(២) ផ្តល់អទិភាពខ្ពស់ដល់ការស្តារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹកនៅតាមតំបន់ដែលភាពក្រីក្រមានកម្រិតខ្ពស់ ឬពិនិត្យឃើញថាមានសក្តានុពលទឹក។

(៣) ជំរុញឱ្យមានការថែទាំ និងពង្រីកបន្ថែមនូវអាងតម្កល់ទឹក ស្រះទឹក ប្រឡាយនាំទឹក និងប្រព័ន្ធដោះទឹក

ដើម្បីធានាដល់ការផ្គត់ផ្គង់ទឹកសម្រាប់ផ្ទៃដីបង្កបង្កើនផល ជលវប្បកម្ម ជីវភាពរស់នៅប្រចាំថ្ងៃ សត្វពាហនៈ ។

(៤) ជំរុញការផ្សព្វផ្សាយបច្ចេកវិទ្យាគ្រប់គ្រងទឹកសមស្របមួយក្នុងតំបន់កសិកម្ម ដែលពឹងផ្អែកលើទឹកភ្លៀង ។

(៥) ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងដល់មន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ទាំងបុរស និងស្ត្រី ដើម្បីអនុវត្តវិធីសាស្ត្រ និងបច្ចេកវិទ្យាស្រោចស្រព និងដោះទឹក ។

(៦) ប្រមូលផ្តុំឱ្យមានការចូលរួមពីកសិករ ជាពិសេសកសិករស្ត្រីអ្នកពាក់ព័ន្ធ និងផ្នែកឯកជននៅគ្រប់ដំណាក់កាលនៃការរៀបចំគម្រោង ការកែលំអ ព្រមទាំងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹក ។

(៧) ជំរុញការសិក្សា និងរៀបចំផែនការអភិវឌ្ឍន៍អាងទន្លេសម្រាប់រយៈពេលខ្លី មធ្យម និងវែង ព្រមទាំងគិតគូរដល់ការប្រែប្រួលធារទឹកទន្លេ ការផ្លាស់ប្តូរចរន្តទឹក និងល្អាងទឹកធម្មជាតិក្រោមដី ដើម្បីធានាដល់ការប្រើប្រាស់ធនធានទឹកនាបច្ចុប្បន្ន និងពេលអនាគត ។

(៨) ផ្តោតការយកចិត្តទុកដាក់លើកិច្ចប្រឹងប្រែងលើអាងស្ទឹងអាទិភាព ព្រមទាំងអភិរក្សលទ្ធភាពល្អាងទឹកក្រោមដី ។

(៩) អនុវត្តនូវវិធីសាស្ត្រចម្រុះចំពោះការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក ដោយគិតគូរឱ្យបានច្បាស់លាស់ពីប្រភពទឹក ការផ្សារភ្ជាប់គ្នារវាងធនធានទឹកជាមួយនឹងផ្នែកផ្សេងទៀតនៃបរិស្ថាន ការប្រែប្រួលនូវតម្រូវការរបស់មនុស្ស និងបរិស្ថានមកលើធនធានទឹក ព្រមទាំងតម្រូវការនូវវិធីសាស្ត្រផ្សេងនានា ក្នុងការអនុវត្តការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ។

(១០) បង្កើនការយល់ដឹង និងជំរុញការរៀបចំ ការអនុវត្តផែនការគ្រប់គ្រង និងផែនការអភិវឌ្ឍអាងទន្លេ ដោយមានការចូលរួមសហការពីស្ថាប័នពាក់ព័ន្ធ អ្នកពាក់ព័ន្ធ និងអ្នកទទួលផល ជាពិសេសស្ត្រី ។

(១១) ជំរុញឱ្យមានការចូលរួមពី ស.ក.ប.ទ អ្នកទទួលផល និងផ្នែកឯកជននៅគ្រប់ដំណាក់កាលនៃការអភិវឌ្ឍ និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹក ។

(១២) បង្កើនសមត្ថភាពសហគមន៍កសិករប្រើប្រាស់ទឹក (ស.ក.ប.ទ) ស្តីពីរបៀបគ្រប់គ្រង ថែទាំ និងកិច្ចដំណើរការប្រព័ន្ធធារាសាស្ត្រ ដោយមានការចូលរួមពីអ្នកទទួលផល និងកិច្ចអភិវឌ្ឍន៍ ។

(១៣) ជំរុញការវិនិយោគពីភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ ព្រមទាំងផ្នែកឯកជន ដើម្បីទ្រទ្រង់ដល់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដោយមានការចូលរួមពីអ្នកទទួលផល និងកិច្ចអភិវឌ្ឍន៍ ។

(១៤) បង្កើនប្រាក់ចំណូល តាមរយៈផ្នែកធារាសាស្ត្រកសិកម្ម និងធានាបន្តការវិនិយោគក្នុងវិស័យធនធានទឹកសម្រាប់ការផលិតដំណាំ ។

## ៤.២_ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត

ដោយស្ថានភាពភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅផ្នែកខាងក្រោមនៃអាងទន្លេមេគង្គ ទទួលរបបខ្យល់ខ្យល់មូសុងនោះ បានធ្វើឱ្យប្រទេសកម្ពុជាតែងជួបប្រទះគ្រោះមហន្តរាយធម្មជាតិ ដូចជាទឹកជំនន់ ព្យុះ និងគ្រោះរាំងស្ងួតជាបន្តបន្ទាប់ ។

គ្រោះមហន្តរាយធម្មជាតិនានាដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ច្រើនតែពាក់ព័ន្ធទៅនឹងទឹក ហើយនិង

អាកាសធាតុដូចជា ភាពរាំងស្ងួត និងទឹកជំនន់ ដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង ជាពិសេសដល់កសិករក្រីក្រនៅតាមជនបទ។ ជារៀងរាល់ឆ្នាំ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ទ្រព្យសម្បត្តិ ផ្ទះសម្បែង និងអាយុជីវិតរបស់ប្រជាជនត្រូវបានគំរាមកំហែង និងខូចខាតធ្ងន់ធ្ងរដោយសារគ្រោះទឹកជំនន់ ដែលជាកត្តាចំបងមួយធ្វើឱ្យរាំងស្ទះដល់ដំណើរការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិ របស់រាជរដ្ឋាភិបាល។

ប្រទេសកម្ពុជាសំបូរទៅដោយធនធានទឹក ដែលមានទន្លេមេគង្គ បឹងទន្លេសាប និងប្រព័ន្ធស្ទឹងនានា។ ទន្ទឹមនឹងនេះ នៅរដូវវស្សាមានទឹកសំបូរហូរហៀរ ហើយនៅរដូវប្រាំងប្រជាកសិករ ជួបប្រទះនឹងការខ្វះខាតទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងកសិកម្ម នៅផ្នែកខ្លះនៃប្រទេសកម្ពុជា ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងទ្រព្យសម្បត្តិរបស់ប្រជាជន បានទទួលរងការខូចខាតដោយសារគ្រោះពីទឹកជំនន់ និងគ្រោះរាំងស្ងួត។

ម្យ៉ាងទៀតការគំរាមកំហែងបង្កឡើងដោយមហន្តរាយ ដែលពាក់ព័ន្ធនឹងទឹកកាន់តែមានសភាពធ្ងន់ធ្ងរឡើង នៅពេលចំនួនប្រជាជន ទ្រព្យសម្បត្តិជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចមានការកើនឡើង។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងធានាដល់កិច្ចការពារ និងការកាត់បន្ថយនូវការបាត់បង់អាយុជីវិត ទ្រព្យសម្បត្តិប្រជាពលរដ្ឋក៏ដូចជាទ្រព្យសម្បត្តិសាធារណៈពីគ្រោះមហន្តរាយ បង្កឡើងដោយមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ក្រសួងធនធានទឹក និងឧតុនិយម **មានផែនការសកម្មភាព**ដូចតទៅ ÷

(១) ជំរុញ និងយកចិត្តទុកដាក់ដល់ការសិក្សា និងការសាងសង់ទំនប់ការពារ ព្រមទាំងប្រឡាយដោះទឹកជំនន់ក្នុងគោលបំណងកាត់បន្ថយឱ្យបានជាអតិបរមានូវគ្រោះមហន្តរាយធម្មជាតិ ដែលបណ្តាលមកពីទឹក។

(២) អនុវត្តនូវវិធានការនានា ក្នុងការកាត់បន្ថយទឹកជំនន់នៅគ្រប់ទីកន្លែង ដែលផ្តល់នូវសក្តានុពលសេដ្ឋកិច្ចខ្ពស់ តាមរយៈការអប់រំសហគមន៍ ការផ្តល់ព័ត៌មានជាសាធារណៈ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។

(៣) ឆ្លើយតបជាបន្ទាន់នៅតំបន់ដែលទទួលរងគ្រោះដោយឥទ្ធិពលនៃភាពរាំងស្ងួត ទឹកជំនន់ និងមហន្តរាយបង្កឡើងដោយទឹក។

(៤) បន្តលើកទឹកចិត្ត ព្រមទាំងជំរុញដល់ប្រជាពលរដ្ឋគ្រប់រូប និងគ្រប់ស្ថាប័នឱ្យចូលរួមលើវិធានការកាត់បន្ថយគ្រោះទឹកជំនន់តាមមធ្យោបាយនានាដូចជា ការរៀបចំទីទួលសុវត្ថិភាពការផ្គត់ផ្គង់សំភារៈ បរិក្ខារ គ្រឿងចក្រ ការសិក្សាអប់រំ ការបង្ហាញនូវបច្ចេកវិទ្យាថ្មីៗ សមស្របទៅតាមស្ថានភាពជាក់ស្តែង។

(៥) ចូលរួមយ៉ាងសកម្មក្នុងកម្មវិធីជាតិ អន្តរជាតិ និងតំបន់ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់នៃគ្រោះមហន្តរាយដែលបង្កឡើងដោយទឹក។

(៦) ត្រៀមលក្ខណៈចុះអន្តរាគមន៍បូមទឹកសង្គ្រោះដំណាំស្រូវប្រាំង និងស្រូវវស្សាពេលជួបការខ្វះទឹក និងគ្រោះរាំងស្ងួតជូនប្រជាកសិករនៅគ្រប់ខេត្ត ពិសេសនៅទីតាំងណាដែលស្ថិតជិតប្រភពទឹក ហើយគ្មានបណ្តាញស្រោចស្រពបង្ហូរដល់។

## ៤.៣_ការជំរុញរៀបចំច្បាប់_បញ្ញត្តិ និងនិរន្តរភាពនៃទឹក

ការគ្រប់គ្រងធនធានទឹក គឺជាកម្មវិធីដ៏សំខាន់ក្នុងន័យថែរក្សា និងអភិរក្សបរិស្ថានបរិសុទ្ធ។ តែទោះជាយ៉ាងណា

ក៏ដោយ ក៏មានភស្តុតាងជាច្រើនបង្ហាញពីការកើនឡើងនៃសម្ពាធមកលើធនធានទឹក ដូចជាការកាប់ព្រៃឈើ ការនេសាទត្រីដោយប្រើវិធីខុសច្បាប់ ការបង្ហូរទឹកសំណល់ចេញពីទីក្រុង និងទីប្រជុំជននានា ការចាក់សំណល់រឹង និងរាវ ការលេចនិងការបង្ហូរប្រេងពីនាវាចូលទៅក្នុងទន្លេ ស្ទឹង ព្រែក បឹងបួរ និងសមុទ្រ។ ដូច្នេះតម្រូវឱ្យចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការទប់ស្កាត់នូវសកម្មភាពខាងលើ ដូចដែលបណ្តាប្រទេសក្នុងតំបន់ធ្លាប់បានប្រើប្រាស់កន្លងមក ក្នុងកិច្ចការពារធនធានទឹកឱ្យរួចផុតពីការខូចខាត និងការបំផ្លិចបំផ្លាញ។

ច្បាប់ និងគោលនយោបាយស្តីពីការគ្រប់គ្រងធនធានទឹក លិខិតបទដ្ឋាន និងបញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធនឹងទឹកដើរតួយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យរាល់គម្រោងអភិវឌ្ឍន៍ធនធានទឹក។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងធានាការគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាព ព្រមទាំងធានាបាននូវកំណើនសេដ្ឋកិច្ច ក្រសួងធនធានទឹក និងឧតុនិយម **មានផែនការសកម្មភាព** ដូចតទៅ ÷

(១) ក្រោយពីច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា បានចូលជាធរមានមក ក្រសួងធនធានទឹក និងឧតុនិយម បាននឹងកំពុងរៀបចំអនុក្រឹត្យចំនួន ៤បន្ថែមទៀត ក្នុងនោះមាន :

-អនុក្រឹត្យស្តីពីសហគមន៍កសិករប្រើប្រាស់ទឹក

-អនុក្រឹត្យស្តីពីអាជ្ញាប័ណ្ណទឹក និងការចែកចាយទឹក

-អនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ

-អនុក្រឹត្យស្តីពីគុណភាពទឹក

(២) ពង្រឹងព្រមទាំងជំរុញការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹក និងបញ្ញត្តិពាក់ព័ន្ធនានា ដើម្បីត្រួតពិនិត្យ និងទប់ស្កាត់នូវរាល់គម្រោងស្តារឡើងវិញ និងសាងសង់នានាដែលអាចធ្វើឱ្យប៉ះពាល់មកលើធនធានទឹក ក៏ដូចជាប្រព័ន្ធអេកូឡូស៊ី។

(៣) រៀបចំនីតិវិធីក្នុងការវាយតម្លៃ និងការកាត់បន្ថយផលប៉ះពាល់មកលើធនធានទឹក និងសង្គម។

(៤) រក្សាឱ្យបាននូវធារទឹកទន្លេ និងកម្រិតកម្ពស់អប្បបរមាទឹកទន្លេ ស្ទឹង បឹងបួរ ព្រែកដើម្បីធានាដល់ប្រព័ន្ធអេកូឡូស៊ី និងនាវាចរណ៍។

(៥) ហាមឃាត់ និងមានវិធានការជាបន្ទាន់ចំពោះការចាក់បំពេញ ការជីក ឬការរំលោភលើផ្លូវទឹក ទន្លេ ស្ទឹង បឹងបួរ ព្រែកឬក៏ដីទំនាបដែលលិចទឹកជាប្រចាំ និងឆ្នេរសមុទ្រដែលគ្មានច្បាប់អនុញ្ញាត អាចធ្វើឱ្យប៉ះពាល់មកលើធនធានទឹក ក៏ដូចជាប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន។

(៦) ពង្រឹងលើកិច្ចអភិរក្សអាងទឹក បឹងបួរធម្មជាតិដែលមានលទ្ធភាពស្តុកទឹក ដើម្បីជួយសម្រួលដល់ការកាត់បន្ថយនូវទឹកជំនន់ ព្រមទាំងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី។

(៧) បន្តពង្រឹង និងពង្រីកបន្ថែមនូវសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីចូលរួមក្នុងការគ្រប់គ្រងទឹក បែងចែកទឹក និងថែរក្សានូវប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាពខ្ពស់ និងរក្សាបាននូវនិរន្តរភាព។

(៨) រៀបចំអនុក្រឹត្យស្តីពីការកំណត់ទីតាំងភូមិសាស្ត្រនៃប្រព័ន្ធធារាសាស្ត្រ អាងស្តុកទឹក ដើម្បីជៀសវាងការរំលោភបំពាននានាដែលកើតមានឡើង។

## ៤.៤.ការគ្រប់គ្រងព័ត៌មានធនធានទឹក និងឧតុនិយម

គ្រប់វិធានការនានាសម្រាប់កាត់បន្ថយគ្រោះថ្នាក់បង្កឡើងដោយទឹក អាស្រ័យលើទិន្នន័យ និងព័ត៌មានជាក់លាក់ក្នុងការរៀបចំផែនការ និងរៀបចំគម្រោងហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពដូចជា ទំនប់ អាងទឹក ប្រព័ន្ធស្រោចស្រព និងសំណង់ពាក់ព័ន្ធនឹងទឹកដទៃទៀត។ ការប្រកាសភាពអាសន្នក៏ទាមទារឱ្យការព្យាករមានលក្ខណៈត្រឹមត្រូវសម្រាប់ល័ក្ខខ័ណ្ឌអនាគត។

ការព្យាករគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់នៅតាមទន្លេមេគង្គ ទន្លេបាសាក់ ទន្លេសាប ព្រមទាំងដៃរបស់វា និងការវិភាគបាតុភូតផ្សេងៗទៀតនៅក្នុងប្រទេសដើម្បីកាត់បន្ថយគ្រោះមហន្តរាយ ក៏នៅតែមិនទាន់ឆ្លើយតបនូវតម្រូវការជាតិ គឺទាមទារឱ្យមានមូលដ្ឋានទិន្នន័យ និងព័ត៌មានមួយច្បាស់លាស់។

ពុំមានការប្រមូលទិន្នន័យ និងស្រាវជ្រាវច្បាស់លាស់លើវិស័យធនធានទឹក និងឧតុនិយម ដែលជាហេតុធ្វើឱ្យការកសាងនូវប្រព័ន្ធព័ត៌មានវិទ្យាស្តីពីវិស័យធនធានទឹក និងឧតុនិយមមានការយឺតយ៉ាវ។

ប្រទេសកម្ពុជា ជាប្រទេសទទួលនូវរបបខ្យល់មូសុង និងមានអំណោយផលល្អដល់ការអភិវឌ្ឍវិស័យកសិកម្ម។ ការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស និងនៅក្នុងតំបន់បណ្តាលឱ្យកើតមានឡើងនូវជំនន់ និងភាពរាំងស្ងួត។ វិធានការនានាក្នុងការផ្តល់ព័ត៌មាន បង្ការ និងកាត់បន្ថយការខូចខាតនាពេលបច្ចុប្បន្ននៅមានកម្រិត។

បាតុភូតធម្មជាតិទាំងនោះ ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង ជាពិសេសដល់ជីវភាពរស់នៅរបស់ប្រជាកសិករ ដែលប្រកបរបរកសិកម្មលើផ្ទៃដីស្រែចំការនៅវាលទំនាប និងដីទំនាបជាប់សងខាងទន្លេមេគង្គ។

ស្ទើរតែជារៀងរាល់ឆ្នាំទឹកជំនន់ និងភាពរាំងស្ងួត បានបំផ្លិចបំផ្លាញកសិផល ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងអាយុជីវិតប្រជាជនដែលជាកត្តាមួយរារាំងដល់កិច្ចអភិវឌ្ឍន៍ប្រទេស។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងធានាការព្យាករប្រកបដោយប្រសិទ្ធភាព ក្រសួងធនធានទឹក និងឧតុនិយម **មានផែនការសកម្មភាព** ដូចតទៅ ÷

(១) ពង្រឹង និងពង្រីកប្រព័ន្ធឧតុនិយម និងជលសាស្ត្ររាប់បញ្ចូលទាំងការប្រមូលផ្តុំព័ត៌មាន និងការផ្សព្វផ្សាយ។

(២) ធ្វើការព្យាករ និងប្រកាសភាពអាសន្នស្តីពី ភាពរាំងស្ងួត ទឹកជំនន់ និងព្យុះ សម្រាប់រយៈពេលខ្លី មធ្យម និងវែងជាសាធារណៈ។

(៣) កែលំអ និងសាងសង់ស្ថានីយឧតុនិយម និងជលសាស្ត្រ ព្រមទាំងប៉ុស្តិ៍តម្រងទឹកភ្លៀង និងក្តារវាស់កម្ពស់ទឹកនៅតាមទីតាំង និងស្ទឹងសំខាន់ៗ រាប់បញ្ចូលទាំងការប្រមូលទិន្នន័យ និងការផ្សព្វផ្សាយ។

(៤) ដំឡើងប្រព័ន្ធសង្កេតជលសាស្ត្រ ដែលផ្តល់នូវកម្រិតកម្ពស់ទឹកជាក់លាក់ និងទិន្នន័យធារទឹក សម្រាប់គោលបំណងធ្វើការព្យាករ រឺឯទិន្នន័យជលសាស្ត្រប្រើប្រាស់សម្រាប់រៀបចំគម្រោងធនធានទឹក ការគ្រប់គ្រងធនធានទឹក និងប្រើប្រាស់ក្នុងគោលបំណងផ្សេងៗទៀត។

(៥) ដំឡើងប្រព័ន្ធពិនិត្យសង្កេតឧតុនិយម ដើម្បីទទួលបាននូវទិន្នន័យធាតុអាកាសជាក់លាក់សម្រាប់ធ្វើការព្យាករ រឺឯទិន្នន័យអាកាសធាតុប្រើប្រាស់រៀបចំគម្រោង និងប្រើប្រាស់ក្នុងគោលបំណងផ្សេងៗទៀត ។

(៦) ជូនព័ត៌មានការព្យាករអាកាសធាតុ និងណែនាំ អប់រំដល់សាធារណជនឱ្យចេះបង្កា និងទប់ស្កាត់នូវបាតុភូតនានា ដែលបង្កឡើងដោយបម្រែបម្រួលធម្មជាតិ និងអាកាសធាតុ ដូចជា ខ្យល់ព្យុះ រន្ទះ ស៊ូណាមិ ទឹកជំនន់ ជាដើម ។

(៧) រៀបចំសារពើភ័ណ្ឌ និងផែនទីភូមិសាស្ត្រប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធការពារទប់ស្កាត់ទឹកជំនន់ ទំនប់ការពារទឹកប្រៃ អាងទន្លេ-ស្ទឹង ផ្ទៃដីទឹកជំនន់ និងការគ្រប់គ្រងធនធានទឹក ។

## ៤.៥-ការកែលំអការគ្រប់គ្រងរដ្ឋបាល និងអភិវឌ្ឍន៍ធនធានមនុស្ស

នាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងយកចិត្តទុកដាក់យ៉ាងខ្ពស់លើការពង្រឹង និងការកសាងសមត្ថភាពបន្ថែមដល់មន្ត្រីស្ថាប័នពាក់ព័ន្ធនឹងទឹក ជាពិសេសមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ដើម្បីអាចអនុវត្តតួនាទីរបស់ខ្លួនបានក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានទឹក ឱ្យមានប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាព ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានធ្វើការវិលែក និងផ្ទេរភារកិច្ចទទួលខុសត្រូវ មួយចំនួនទៅឱ្យថ្នាក់ក្រោមជាតិ ដូចនេះទាមទារឱ្យមានការបណ្តុះបណ្តាលបន្ថែមទៀតនូវសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ ។ ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងបង្កើនសមត្ថភាពដល់មន្ត្រីគ្រប់លំដាប់ថ្នាក់ ក្រសួងធនធានទឹក និងឧតុនិយម **មានផែនការសកម្មភាព** ដូចតទៅ ៖

(១) បង្កើនការណែនាំជាបន្តបន្ទាប់នូវបែបបទរដ្ឋបាល និងគ្រប់គ្រងតាមរយៈរៀនផងធ្វើការផងដល់មន្ត្រីនៅក្នុងក្រសួងធនធានទឹក និងឧតុនិយម ព្រមទាំងផ្តល់ឱកាសដល់មន្ត្រីជាស្ត្រីដើម្បីឆ្លើយតបតាមស្តង់ដារជាតិ និងអន្តរជាតិ ។

(២) បន្តពង្រឹងសមត្ថភាពមន្ត្រីថ្នាក់កណ្តាល ថ្នាក់ក្រោមជាតិ ទាំងបុរស និងស្ត្រី និងសហគមន៍កសិករប្រើប្រាស់ទឹកឱ្យយល់អំពីអត្ថប្រយោជន៍នៃទឹកចំពោះជីវភាពរស់នៅប្រចាំថ្ងៃ និងការអភិវឌ្ឍសេដ្ឋកិច្ចព្រមទាំងណែនាំឱ្យចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការគ្រប់គ្រង ការថែរក្សា ការអភិរក្ស និងការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់ មាននិរន្តរភាព និងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី តាមមធ្យោបាយនានាដូចជារៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងបញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានសិក្សានានា ដើម្បីធ្វើការផ្សព្វផ្សាយតាមរយៈព្រឹត្តិបត្រព័ត៌មាន ទស្សនាវដ្តី បណ្តាញវិទ្យុ និងទូរទស្សន៍ ។ល។

(៣) រៀបចំបង្កើតបណ្តាញការងារយេនឌ័រគ្រប់មន្ទីរធនធានទឹក និងឧតុនិយម

(៤) បង្កើនការយល់ដឹង និងការវិភាគយេនឌ័រដល់បណ្តាការងារយេនឌ័រមន្ត្រីក្រសួងគ្រប់លំដាប់ថ្នាក់ និងនៅគ្រប់ខេត្ត-រាជធានី ។

(៥) ធានាថាគ្រប់កម្មវិធី និងគម្រោងទាំងអស់នៅក្នុងក្រសួងត្រូវមានការចូលរួមពីក្រុមការងារយេនឌ័រ

# ៥-ស្ថានភាពថវិកា

## ៥.១-ប្រភពថវិកា

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រភពថវិកាសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈភាគច្រើន គឺបាន

មកពីថវិកាជាតិ និងដៃគូអភិវឌ្ឍន៍។ ប្រភពថវិកាសម្រាប់ការងារជួសជុល និងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ ចាប់តាំងពីឆ្នាំ ១៩៧៩ រហូតមកទល់បច្ចុប្បន្ននេះ គឺបានមកពីថវិកាជាតិ និងដៃគូអភិវឌ្ឍន៏រួមមាន ប្រទេសជប៉ុន ប្រទេសបារាំង សាធារណរដ្ឋកូរ៉េ ឥណ្ឌា សាធារណរដ្ឋប្រជាមានិតចិន គូវ៉ែត និងថវិកាមួយចំនួនទៀតបានមកពីការខ្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (WB) មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD) មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) សាធារណរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន សាធារណរដ្ឋកូរ៉េ។ ថ្វីបើមានការផ្តល់ហិរញ្ញប្បទានពីបណ្តាដៃគូអភិវឌ្ឍន៍ខាងលើយ៉ាងណាក៏ដោយ ក៏បណ្តាអង្គការទាំងនោះ ពុំដែលបានគ្រោងទុនសម្រាប់បម្រើការងារថែទាំ និងកិច្ចដំណើរការប្រព័ន្ធធារាសាស្ត្រ ធ្វើឱ្យការថែទាំប្រព័ន្ធធារាសាស្ត្រនៅមានកម្រិតនៅឡើយ។

បច្ចុប្បន្ននេះរាជរដ្ឋាភិបាល បានផ្សព្វផ្សាយ និងពង្រឹងសារាចរ០១ ស្តីពី និរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ សម្រាប់កិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ ដោយបង្កើតឡើងនូវសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីជួយកាត់បន្ថយនូវបន្ទុកថវិការបស់រាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏បានលើកទឹកចិត្តដល់ក្រុមហ៊ុនឯកជន អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ដែលមានបំណងវិនិយោគ និងអភិវឌ្ឍលើការងារធារាសាស្ត្រខ្នាតតូច មធ្យម និងខ្នាតធំ។

## ៥.២_ ចំណាយ និងចំណូលប្រចាំឆ្នាំ

នាពេលបច្ចុប្បន្ននេះ ការប្រើប្រាស់ហិរញ្ញប្បទានបរទេសប្រចាំឆ្នាំ លើការងារអភិវឌ្ឍន៏វិស័យធនធានទឹកនៅកម្ពុជា មានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំយោងទៅតាមប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល និងការទទួលជំនួយពីបរទេស។ ការអភិវឌ្ឍធនធានទឹកអាចជាយុទ្ធនាការមួយដែលទាមទារឱ្យមានការបណ្តាក់ទុនយ៉ាងសន្ធឹកសន្ធាប់។ ពាក់ព័ន្ធទៅនឹងហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា កំពុងអនុវត្តយ៉ាងសកម្មក្នុងការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីប្រើប្រាស់ ថែទាំ និងកិច្ចដំណើរការប្រព័ន្ធធារាស្ត្រដោយខ្លួនឯង ជៀសវាងការពឹងផ្អែកទាំងស្រុងលើថវិការបស់រាជរដ្ឋាភិបាល។ បទពិសោធន៍កន្លងមក បានបង្ហាញឱ្យឃើញថា បើគ្មានការចូលរួមពីសហគមន៍ និងអ្នកទទួលផលលើការប្រើប្រាស់ ថែទាំ និងកិច្ចដំណើរការហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនោះទេ នឹងមានការលំបាកក្នុងការធានាឱ្យមាននិរន្តរភាពនៃហេដ្ឋារចនាសម្ព័ន្ធខាងលើនេះ។

## ៥.៣_តម្រូវការថវិកា

ដើម្បីអនុវត្តផែនការសកម្មភាពស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយម (២០០៩-២០១៣) ទទួលបានជោគជ័យ នឹងឈានទៅសម្រេចបាននូវគោលដៅដែលបានកំណត់ខាងលើ ព្រមទាំងចូលរួមធ្វើឱ្យសម្រេចបាននូវគោលដៅចំបងរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនោះក៏ដូចផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវការថវិកាសរុបចំនួន ១.២៥០.០២៤.០០០US$ ក្នុងនោះថវិការាជរដ្ឋាភិបាលចំនួន ៩៩.៥០០.០០០SU$ ជំនួយបរទេសចំនួន ១.១៥០.៥២៤.០០០US$ ។ ក្នុងជំនួយបទេសទាំងអស់នេះមានតែចំនួន ២០៦.២០០.០០០US$ ដែលបានចុះកិច្ចសន្យាជាមួយដៃគូអភិវឌ្ឍន៍រួច ដូចនេះតម្រូវការថវិកាបន្ថែមពីបទេស ឬដៃគូអភិវឌ្ឍន៍ចំនួន ៩៤៤.៣២៤.០០០US$ ថែមទៀត។ ថវិកាទាំងនោះត្រូវចំណាយតាមបណ្តាឆ្នាំនីមួយៗមានដូចខាងក្រោម :

| ឆ្នាំ | ថវិការដ្ឋ (US$) | ជំនួយបរទេស និងដៃគូអភិវឌ្ឍន៍ (US$) | | សរុបថវិកា (US$) |
|---|---|---|---|---|
| | | បានចុះកិច្ចសន្យា | ស្វែងរកជំនួយ | |
| ២០០៩ | ១៣.៩០២.០០០ | ៣១.២០០.០០០ | 0 | ៤៥.១០២.០០០ |
| ២០១០ | ២៣.៩៦២.០០០ | ៣៨.៧០០.០០០ | ២១១.៧៨៥.០០០ | ២៧៤.៤៤៧.០០០ |
| ២០១១ | ២២.៦៤៥.០០០ | ៥០.៣០០.០០០ | ២២៤.៩៦៣.០០០ | ២៩៧.៩០៨.០០០ |
| ២០១២ | ១៨.០០០.០០០ | ៤៦.៥០០.០០០ | ២៤៥.៧៤៦.០០០ | ៣១០.២៤៦.០០០ |
| ២០១៣ | ២០.៩៩១.០០០ | ៣៩.៥០០.០០០ | ២៦១.៨៣០.០០០ | ៣២២.៣២១.០០០ |
| សរុប | ៩៩.៥០០.០០០ | ២០៦.២០០.០០០ | ៩៤៤.៣២៤.០០០ | ១.២៥០.០២៤.០០០ |

( ជូនភ្ជាប់តារាងទុនវិនិយោគលើវិស័យធនធានទឹក និងឧតុនិយម )

**ឃ. សេចក្តីសន្និដ្ឋាន**

ផែនការយុទ្ធសាស្ត្រ និងសកម្មភាពស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយម ២០០៩-២០១៣ ដែលរៀបចំឡើងដោយក្រសួងធនធានទឹក និងឧតុនិយម ធ្វើឱ្យសម្រេចបានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៩-២០១៣) របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី២ (២០០៩-២០១៣) សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ឆ្នាំ២០០៨-២០១៣ និងគោលដៅចំបងរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

**ង. អនុសាសន៍ និងសំណូមពរ**

ដើម្បីធ្វើឱ្យសម្រេចបាននូវគោលបំណង និងគោលដៅក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យធនធានទឹកឱ្យមាននិរន្តរភាព និងតុល្យភាពបរិស្ថានសម្រាប់ពេលបច្ចុប្បន្នក៏ដូចជាអនាគត ព្រមទាំងធ្វើឱ្យប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់បានយល់ដឹងអំពីអត្ថប្រយោជន៍នៃទឹក និងចូលរួមយ៉ាងសកម្មលើការសាងសង់-ថែទាំ និងប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រឱ្យមានប្រសិទ្ធភាពខ្ពស់សំដៅកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនោះ **ទាមទារឱ្យមានការប្តេជ្ញាចិត្តខ្ពស់ និងគាំទ្រយ៉ាងពេញទំហឹងទាំងផ្នែកបច្ចេកទេស និងថវិកាពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បណ្តាប្រទេសផ្តល់ហិរញ្ញប្បទាន និងមានការចូលរួមពីស្ថាប័នពាក់ព័ន្ធនានាក្នុងស្តារ និងអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយមនៅកម្ពុជា។**

ក្រសួងធនធានទឹក និងឧតុនិយម សំណូមពរដល់រាជរដ្ឋាភិបាលជួយជំរុញលើកទឹកចិត្តដល់អង្គការជាតិ អង្គការអន្តរជាតិ និងបណ្តាប្រទេសផ្តល់ជំនួយចូលរួមក្នុងការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយម។ ពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្តផ្តល់ថវិកាឱ្យបានទាន់ពេលវេលា និងស្ថាប័នពាក់ព័ន្ធបន្តសហការលើការងារដែលពាក់ព័ន្ធវិស័យធនធានទឹក។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៩

រដ្ឋមន្ត្រី

លឹម គានហោ